# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហួតនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះគ្រូបញ្ញាលិក្ខិត កៅ-ស៊ុម អ្នកត្រួតត្រា
សិស្ស នៅសាលាបាលីជាន់ខ្ពស់

## បញ្ជីរឿង

ទំព័រ

### ផ្នែកអក្សរសាស្ត្រ

ឧកញ៉ា មេត្រីទូ-ក្រសេម .... ប្រវត្តិស្ដេចកែះស្ដេចភ្លង (តមក) ..... ៣១៣

វណ្ណគតិ តារាយណ៍ ទសាវតារ (តមក) .. ៣២១

" " " 

ហួតនិពន្ធមន្ត្រី ញ៉ុក-ថែម .... ពង្សាវតារប្រទេសចិន (តមក) ...... ៣៣៨

ឃុនឧត្តមប្រីជា ពាប-ពិន .. រឿងព្រះសុភ សិលខ្មែរ (តមកនិងចប់) ... ៣៥២

### ផ្នែកដំណឹងសាសនា

ឃុនសេវកភណ្ឌភក្តិ អ៊ុំ-កន ... ក្បួនពុទ្ធជាតក .......... ៣០៩

ឆ្នាំទី ៣០ លេខ ១២ ខែដេសេម្ប្រ៍ ១៩៥៨ - ថ្លៃលក់: ១ ឆ្នាំ ១៥ រៀល

# ប្រវត្តិស្តេចចឹកាស្តេចកើង

## ឧកញ៉ាទេពពិទូរ ក្រឹសេម

### រៀបរៀង (តទៅ)

នាកាលកំណាលអំពីបុរាណៈរៀងរ៉ៅ មកនោះ ៣ ឆ្នាំក៏ឲ្យឡើងមក ស្ទួរមួង ក៏ឥឡូវនេះ ត្បូងមានកន្ទុលផ្លូវក្រោមនេះឯង កើតក្នុងខគល គម្ពីរនេះ ទេព្វបានឲ្យមក្កុបៅក់ ។

អំពីនេះ ខ្ញុំបានពិពណ៌នាសេចក្តីតាមក្រោនគុជក្រុងកម្ពុជាក្រុងតាំង ២ ប្រាប់នេះ ឲ្យជាខ្លាតរបៀបនៅ :–

តាមសេចក្តីខាងចុងនៃព្រះរាជក្រឹត្យតាំងស្តេចចិកស្តេចកើងថ្វាក់ថា ស្តេចចិកស្តេចកើងមានមកតាំងពីបុរាណកាល កំណត់ក្នុងរាំង ៣ ឆ្នាំ ស្តេចខ្មែរនេះមានចាត់កជខ្ញុំក្បួនមកបួរក្ខង រៀងកល់ត្រែកវ្វ តែនេះតាំងខគមកជាយូរឆ្នាំហើយ ព្រោះមានកន្ទុលផ្លូវក្រោម ។ ក្នុងពាក្យថា ៣ ឆ្នាំឲ្យមកស្ទួរមួង នោះអ្នកស្រុកនៅស្រុកសំបុកក្លែខៅទំណាមិនបានគោល ផល់ លុះមកដល់វេលាព្រះបាទសម្តេចព្រះស្រីសុរិយោពណ៌ ក្រោយ ដែលទ្រង់ឡើងសោយរាជ្យបាន ១ ឆ្នាំគឺគតិឆ្នាំមមែសកកព្ទ ១៥២៣ (គ.ស. ១៦០១) ទ្រង់ព្រះត្រួដល់រឿងសម្ពន្ធមេត្រីរាំងស្តេចចិកស្តេច កើង សង្ឃរាលកប់ពីរមកយូរហើយ ទើបទ្រង់ឲ្យរៀបចំតែងតាំងគាត់ ឡើងវិញ របៀបដែលតែងតាំងក្នុងពេលនោះ តាមដែលប្រាកដក្នុងព្រះ

ះកដក្រស្យាន់ពរនេះ . គឺកំណាយកស្រកសំបុក គង់នៅតែក្រពះ ជាតួព្រះខ័ន ហើយនិងតម្កើងទីខ័ន ស្តេចទឹក ស្តេចភ្លើង សម្រាប់ពេញចូល តាមការគ្នាសម្ពន្ធនេះ, ខាងការព្រះពុទ្ធសាសនា ទ្រង់រាជឲ្យមានវត្តសំបុកចុកជាគោលនៅក្នុងព្រះខ័ន ក្រៅអំពីនេះ តាមផ្លូវចាស់ព្រឹទ្ធាចារ្យចាស់ៗឡើយ ហៅតំបន់នេះសំបុកដំណាលមក្ខវា ទ្រង់ឲ្យរើសរកទីសម្រាប់ទុកផ្ទុំជុំ ស្តេចទឹក ស្តេចភ្លើង នៅតំបន់ព្រះខ័ន ១ គឺអ្វីរើសបានទួល ១ ធំ ទំហំប្រមាណ ៤ គីឡូម៉ែត្រ ៦ ជ្រុង នៅជាខាងទិសនិរតីនៃវត្តសំបុក ចម្ងាយប្រមាណពីរគីឡូម៉ែត្រកន្លះពីវត្តសំបុកដែលហៅថា "កេងដាវ" ក្នុងពេលនោះ ប្រហែលជាមានធ្វើព្រះពន្លាបណ្ដោះអាសន្នសម្រាប់ទុក ស្តេចទឹក ស្តេចភ្លើង ហើយមានដីកើតសម្រាប់សំបកដាវតាំងសងខាងផង ទី នោះទើបមានឈ្មោះថាកេងដាវ ដកចមកដល់សព្វថ្ងៃនេះ ក្រៅអំពីនេះ ការខាងលទ្ធិសៃយ ទ្រង់បានឲ្យសាងក្រសមអ្នកតា ១ ប្រគល់ឲ្យអ្នកតាខាងការពារទុកនៅទួលកេងដាវ ដែលជាតួព្រះខ័ន ជាគ្នាទីវត្តសំបុក អ្នកតានេះមានរូបជាថ្មចំធម្មតា សព្វគេជាបអ្នកតា ហៅថា "អ្នកតាព្រះអង្គព្រះខ័ន" តែជួនកាលគេហៅថា "អ្នកតាស្តេចទឹក ស្តេចភ្លើង" ក៏មាន ហៅថា "អ្នកតាកេងដាវ" ក៏មាន ; របៀបពិធីឡើងអ្នកតានេះដូច មួយនឹងមានអញ្ជើញទៅខាងក្រោម ៗ

កន្លងឆ្នាំនោះ ទ្រង់បានចេញព្រះរាជក្រឹត្យ ១ ច្បាប់ (ដូចមានខាងលើនេះ) ត្រូវតាំងស្ដេចទឹកស្ដេចភ្លើងឡើង ការរើសខ្ញុំតាំងជាស្ដេចនេះ ត្រូវចុះឈ្មោះពួកពូជគេរើសគ្នាគេ, រើសរើសផលជាសំខាន់ពូនចំណាលមកថា កាលជាន់ដំបូងនោះ គេរើសបានឈ្មោះណាកូនក្រកូលណា តាំងឲ្យធ្វើស្ដេចទឹកស្ដេចភ្លើងហើយ ដល់ត្រាក្រោយមកកាលផុតអំពីឈ្មោះនោះហើយ ត្រូវរើសកូនក្រកូលដែលនោះតាំងជំ-នួសតទៅ ចំនួនដូចជារើសព្រះរាជវង្សឲ្យឡើងរាជ្យដូច្នោះ ។ ការរើសខ្ញុំកូនជួកាលនោះ រើសតាមលំអាននេះ ឬ រើសដូចម្ដេចកូនព្រះរាជ-ក្រឹត្យមិនបានពោលដល់ តែមើលឃើញប្រវេណីរើសតាមវង្សត្រកូលមកអំពីដើមម្ល៉េះ គង់ជារើសតាមទំនៀមនោះ ។ ការរើសខ្ញុំតាំងកូនត្រានោះ ប្រាកដជាមានពីរអង្គ គឺ ១ អង្គជាស្ដេចទឹក ១ អង្គទៀតជាស្ដេចភ្លើង, តាំង ៤ នេះនាមដើមជាអ្វីមិនប្រាកដ (ហើយមានពោលតទៅទៀតថា បើកាលណាអង្គឯណាមួយសុគតទៅហើយ ត្រូវតាក់ការតាំងជាថ្មីជំណាងវង្សឡើងវិញជាដរាប) ។ តាមដែលអ្នកស្រី បូរ៉េ ចំណាលប្រាប់ថា "មានអ្នកប្រាជ្ញពីរនាក់ឈ្មោះម៉ែត្រ (Maitre) និង ហង់រី-ម៉ាសប៉េរ៉ូ (Henri maspéro) បាននាំពាក្យដល់ទីកន្លែងនោះហើយបានជួបជាល់នឹងស្ដេចទឹក ។ ដោយន័យនេះ គប្បីជឿថា ស្ដេចទឹកស្ដេចភ្លើងមានពីរអង្គ ។

ក្នុងគ្រានោះ ព្រះបាទសម្តេចព្រះស្រីសុរិយោពណ៌ ទ្រង់តាំងមន្ត្រីដែលមានបញ្ញាគោរម្យឆ្លាតប្រាកដ ៣ នាក់ គឺចៅពញាទេសអន្ស ១ ចៅពញាធិកពិការ ១ ចៅពញាធិកបរិយោ ១ ជាកងខ្ពង់ ឲ្យនាំព្រះរាជសាស់ន៍ ទូកងាយណ្ណ៏ការឡើងដំរីទៅរៀបតែងតាំងស្តេចទឹកស្តេចភ្លើង, តាំងពួនក៏ចុះមកជួបជុំនៅទីនោះ រៀបពិធីតែងតាំងដូច្នេះ ។

មុននឹងតែងតាំង ត្រូវធ្វើពិធីឡើងអ្នកតាតាមទំនៀមសិន ក្នុងព្រះរាជក្រឹត្យគ្មានពោលដល់ ព្រោះជាទំនៀមធម្មតាតែងតែមានរៀងរហូតមកហើយ តែប្រាកដតាមដែលចាស់ទុំព្រឹទ្ធាចារ្យទាំងឡាយនៅស្រុកសំបុកឲ្យការ ដូចមានប្រាកដក្នុងសេចក្តីកត់រឿងស្តេចទឹកស្តេចភ្លើង (១) របស់លោកញូង សឿង ក្រុមពុទ្ធសាសនបណ្ឌិត្យថា.. ការឡើងអ្នកតានៅទីនោះ គឺឡើងអ្នកតាព្រះអង្គព្រះចន្ទ ដែលជាអ្នកតាខាងពួង អ្នកតានេះមានបុរស ១ នាក់ដែលអ្នកស្រុកគេតាំងឡើង ឲ្យជាអ្នកធ្វើការបរិក្ខុង ពេលដែលមានពិធីឡើងអ្នកតា ហៅថា "ដំបងអ្នកតា" ប្រែបយ៉ាង ហៀងក្នុង (២) របស់អ្នកតាចិន; ពិធីក្នុងឱកាសតែងតាំងស្តេចទឹកស្តេចភ្លើង នឹងក្នុងពេលដែលស្តេចនេះនាំសួយមកឡើងស្តេចខ្មែរ ក្នុងវេលាប្រជុំខួបត្រីត្បូមួង ៗ នោះ ជាពិធីជាយក្សែក, ក្រៅអំពីនេះ ក៏មានជាធម្មតា

១ មានទេពុទ្ធសាសនបណ្ឌិត្យ លេខ ៨៨–១៥ ។ ២ អ្នកតាធំ ៗ របស់ចិនតែងមានអ្នកនៅបំរើ ស្រម និងបម្រើការផ្សេង ៗ ហៅថាហៀងកុង ។

រៀនកល់ឆ្នាំ តែក្រោយនេះជាពិធីតូច ៗ ពិធីការខាងដើមនោះមានរបៀប ដូចគ្នា ៗ ក្នុងឱកាសកាំទៅស្រុកខ្មែរស្ដេចក្រុងនោះ កាលមកជួបជុំគ្នាហើយ គេរៀបធ្វើឡើងអ្នកតាជាមុនសិន តែរបៀបធ្វើដូចម្ដេចខ្លះ គេមិនដាចខាត របៀបបញ្ចប់ឲ្យសព្វគ្រប់ទេ ព្រោះកាលកន្លងមកយូរហើយ មានគ្រឿង សង្ហើយអ្នកតាតាមដែលគេអាចចាំបាន គឺក្បាលជ្រូកស្ងោរ(១) ១ ទាស្ងោរ ១ គូ មាន់ស្ងោរ ១ គូ មាន់អាំង ១ គូ ចំអាប ១ ស្ពត បង្អែម ១ ស្ពត ផ្កាយដំណើប ១ ចាន បាយសីធុកផាម ១ គូ ស្លាធម៌ ១ គូ ស្លាជម ៤ ស្រាស (គឺស្រាក្លង) ១ ពាង ។ ក្នុងពិធីនេះមានរូបសំណាកសម្រាប់ បញ្ចូលអ្នកតាផង តែរូបសំណាកនោះជាខ្មែរ ចាំងក្មេងដែលលេងក៏ជា របស់ខ្មែរ ក្នុងពេលឡើងអ្នកតាកាល់ ៗ ផងនោះ ពួកអ្នកស្រុករមែងយក អំបោះសមកថ្វាយអ្នកតា ។ សុំឱ្យអ្នកតាប្រសិទ្ធពរឲ្យ ហើយយកទៅចងក ចងដៃកូនចៅវិញ ដើម្បីកុំឲ្យមានជម្ងឺដំកាត់ដោយត្រូវពួកខ្មោចបិសាច ជាដើម ។ អ្នកតានេះមានរឿងចំឡែក គឺចូលចិត្តសោយតែស្រាអេក តាមទំនៀមគាង ទីងថ្វាយស្រាឯទៀតគុំព្រមទទួល ។ ឯពាងដែលដាក់ ស្រានោះ កាលស្រេចកិច្ចឡើង ទីងយកទៅផ្ទះក្រោមពុំបាន ត្រូវទុកនៅ ទីអាស្រមនោះ ១ អាទិត្យទើបយកទៅបាន ។

---

១ អំពី.ដឹម ឬហៅណាមាតកាប់ក្របីថ្វាយ ព្រោះទំនៀមក្នុងស្រុកនៃតែធ្វើដូច្នេះ ៗ

កាលរៀបអង្គការរួចហើយ គេរៀបចំលៀនស្ដេចទឹកស្ដេចភ្លើង តាមរបៀបដែលចំលៀននោះ គេអង្គាសពួកកស្រុកនៃស្រុកនោះឲ្យយកមក កាលផ្ទះក្នុងមួយផ្ទះឲ្យមានមាន់ស្ងោរ ១ មាន់អាំង ១ នឹងបាយដំណើបបួ បាយខ្យាយ ១ ចាន ខ្លះបង្ហូបចំណីយ៉ាងដទៃទៀតតាមដែលមាន រួមទាំងស្រាបផ្អែកដែលគេសម្រាប់យកទៅក្រាលថ្វាយអ្នកតាមោរពង ។

ស្រេចកិច្ចរៀបចំលៀនគ្នាហើយ ក្រវេត្តិពិធីតែងតាំងស្ដេចទឹកស្ដេចភ្លើង ដោយរបៀបដែលមានមកដូចនេះ មុននឹងចូលពិធីតែងតាំង ត្រូវឲ្យយកទឹកសំបួរកក់ជំរះអង្គអ្នកដែលនឹងតាំងជាស្ដេចទឹកស្ដេចភ្លើងឲ្យស្អាត លាបប្រេងលាបម្សៅ ហើយទើបឲ្យតែងខ្លួនស្លៀកពាក់តាមភេទរបស់គេ, លុះដល់ពេលនោះគេយកគ្រឿងកដបំណាក់ការតាំងបុរាណ ដូចមានពោលមកខាងលើនេះរៀបរៀងជា ២ ជួរស្មើគ្នា គឺ ១ ភាគសម្រាប់ថ្វាយទៅស្ដេចទឹក ១ ភាគទៀតសម្រាប់ថ្វាយទៅស្ដេចភ្លើង រួចហើយគេអញ្ជើញអ្នកសាមីខ្លួនទាំងពីរនាក់ឲ្យទៅអង្គុយខុំមគ្នា នៅទីដើមកាសខ្មាំង ។ ខណៈនោះ ចៅពញាធិកបរហោយកពាក្យប្រមែនតារីព្រះរាជសារព្រះករុណាក្រុងកម្ពុជាមកថ្វាយកំណាន់ព្រះអង្គ តាមថែបម្ដីរ៉ូកាលព្រះបាទសម្ដេចព្រះស្រីសុរិយោពណ៌ថា "ព្រះរាជទត្ដា" មមេសាវសេនរបស់ព្រះទ្រាព្យទមណ្ឌល វិមលសោភ័ណ្ឌ បរមនិពាសារសព្វមង្គលឧទ្យានបង្កែង ខៃព្រះចៅក្រុងកម្ពុជាធិបតី ។ ល ។ (១)

---

១ សេចក្ដីពិស្ដារនៃបមានភាគលើនោះស្រាប់ ។

ឲ្យកប់ខ្ទះគេផងគប់ ដែលស៊ិវិប្រើស្ត្រី ឲ្យអស់ទេព្ទះខ្ពាក់ស្រុកក្រ ផងក្រុង ម្រនកាយុស់ឲ្យនេះ យើងយូរប៉ប៉ូរកេះ ថ ចំកាលវិជ្ជាទៅ ហៅន ។ ហើយ ស្ត្រីមាមក ណាំប្រកាបតាំងថា ព្រះណោះ... ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទ្រង់ព្រះទេត្តាតាំងជា ស្តេច ហៅថា "ស្តេចទឹក" ឯងលោកណោះ... ក្រោយបានតាំងជាស្តេច ហៅថា "ស្តេចភ្លើង" ឲ្យស្រុក ៗ ចប់ ហើយមានប្រជាការសាគេផង វេលា ស្រុកចប់ ក្រួលេងក្រុងក្លាក់ពុំប៉ុមេឃ្លុំ ប្រកំដោយខ្សែសាសនគេ ។ និយាយតាមទំនៀមកទំនះនេះ តុយុក ព្រះទ័ខឧំង ព្រះរាក់ ដែលជា របស់សម្រាប់ស្តេចទឹកស្តេចភ្លើងពីបុរាណកាលមកនោះ ប៉ាឃទៅផង គឺ ព្រះទ័ ថ្វាយជាស្តេចភ្លើង ព្រះរំពាក់ថ្វាយទៅស្តេចទឹកជាអាផស ម្រាប់ យស់សក្ការបស់ ស្តេចទាំងពីរ តែកងកជគ្រឿងថ្នាំទទៅលដល់ ប៉ុណ្ណោះ កប់ជា ស្រេចក្ដីពិធីកែងតាំងស្តេចទឹកស្តេចភ្លើង ។

## មុខការស្តេចទឹក ស្តេចភ្លើង

លុះធ្វើពិធីតែងតាំងរួចហើយ ស្តេចទឹកស្តេចភ្លើងក៏យករបស់ទ្រព្យ ដែលស្តេចខ្មែរព្រះករុណាផ្ញើទៅ ត្រឡប់ទៅស្រុកវិញ ។ ស្តេចទាំង ពីរនេះនេះក្នុងរូបក្លដែរបជាលិខិតរបស់ស្តេចទឹក ស្តេចភ្លើង អំពីបុរាណ កាលមក ដូចបានពោលរួចហើយ ក្នុងពេលនោះ ប្រហែលជាមានពួក មនុស្សព្រៃ ពួកយាងរ៉ាវ ព្រាយ ពូន ជាដើម នាំគ្នាមកចូលសំដែង សេចក្ដីស្វាមីភក្ដីផងជា ប្រើន ។

(អា-គ)

[illegible]

# នារាយណ៍ ទសាវតារ

ឧកញ៉ាទេពពិទូរ ក្រសេម រៀបរៀង

(តមក)

នាងម៉ែត្រខ្លួនជាពពកមួយដុំប្រមាណប៉ុនមេដៃ ហើយអណ្ដែតចូលទៅក្នុងមាត់នាង ហើយត្រឡប់ចេញមកវិញ ដោយនាងឥតដឹងខ្លួនសោះ នាងស្រស់សាស់សើរ ហណុមានជាច្បាស់ ហើយបើកផ្លូវឲ្យទៅ ប្រែខ្លះនាងកក្រសែសមុទ្រឈ្មោះសង្ឃិកា ក៏ស្រោះនាង ហើយ ក៏ហោះទៅផល់ល្អក្ដ ហើយចាប់កេតនាងសីតា ត្រប់ស្រុះ សាទពជ្ជកខុង ព្រះ ក៏ទំប៉ុត ទៅពេញឧទ្យានអសោក ទើបឃើញនាងសីតាកំពុងត្រូវពួកនាងយក្សពាម ក្រោមដើមប្រធូជំរៀងៗ នាងគិតនឹងចង់សម្លាប់ខ្លួន ហណុមានឃើញទុក្ខសោកស្រល ទើបចុះអំពីដើមឈើមកថ្វាយបង្គំទូលតាមរឿងដោយល្អិត ហើយថ្វាយព្រះធ្រមង់ (ចិញ្ចៀន) ហណុមានទទួលអាសានឹងនាំនាងទៅជួបព្រះរាមវិញ នាងមិនព្រមទៅ ដោយគិតឃើញថាមិនសមគួរនឹងឲ្យប្រុសមកប៉ះពាល់ខ្លួននាងទៀត តែនាងផ្ដាំហណុមានឲ្យទៅទូលព្រះរាម នឹងផ្ញើសិក្ខាភរណៈមួយទៅថ្វាយជាភស្តុតាង ហណុមានថ្វាយបង្គំលានាង ទៅទឹកចិត្តនឹងសហណុ ក៏កាប់សួនខ្ទេចខ្ទីអស់ រាល់តែកើតរឿងច្បាំងគ្នានឹងសេនាប្រហស្ត, អក្សកុមារ ឥន្ទ្រជិតចងសរនាគបាសរួបរឹតហណុមាន នាំយកទៅថ្វាយក្រុងរាពណ៍ ហណុមានបានបញ្ឆោតឲ្យក្រុងរាពណ៍យក

ភ្លើងអុជកន្ទុយ ហនុមានក៏ដុតក្រុងលង្កាខ្ទេច ហើយទៅលត់ភ្លើងនៅកន្ទុយនោះឯមហាសមុទ្រ ហើយហោះត្រឡប់មករកអង្គទនិងពួកពានរ ដែលទៅចាំនៅលើភ្នំមហេន្ទ្រ នាំគ្នាទៅទូលព្រះរាមតាមដំណើរគ្រប់ប្រការ ។

ព្រះរាមត្រាស់ឲ្យលើកទ័ពទៅបោះនៅឆ្នេរសមុទ្រ ។ ខាងលង្កាឯណោះបានប្រឹក្សាគ្នាថា នឹងធ្វើប្រការម្ដេច ពួកយក្សក៏អួតប៉ុនខ្លាំងពូកែទៅផ្សេងៗ មានតែពិភេកណ៍មួយទូលទាស់ថា គួរបញ្ជូននាងសីតាទៅវិញ ព្រោះមានប្រផ្នូលអាក្រក់ជាច្រើនប្រការ. ក្រុងរាពណ៍ក្រោធបណ្ដេញពិភេកណ៍ចេញពីព្រះពន្ធគំនាល់, ពិភេកណ៍ចេញចាកក្រុងលង្កាព្រមដោយសេនា ៤ នាក់មកសុំពឹងព្រះរាម ។ ព្រះរាមត្រាស់ឲ្យរកផ្លូវដើរទឹងសមុទ្រ (ទេវតារក្សាសមុទ្រ) សទូលអ្នកចាំយាមស្រែកបាលឃើញពួកពលពានរមកដល់ឆ្នេរសមុទ្រ ក៏រួសរាន់នាំស្របក្ដីទៅទូលក្រុងរាពណ៍ ។ ប្រើសុកៈឲ្យទៅរកសុគ្រីពដើម្បីផ្សះផ្សាគ្នាដោយស្រួល ឲ្យលើកទ័ពត្រឡប់ទៅកិស្កិន្ធវិញ ពួកពានរចាប់សុកៈបាន ព្រះសមុទ្រមិនឡើងមក ព្រះរាមទើបបាញ់សរព្រហ្មាស្ត្របាញ់មហាសមុទ្រឲ្យរីងស្ងួត ព្រះសមុទ្រឡើងមកទូលថា ឲ្យចងថ្នល់ឆ្លងទៅចុះ ទើបបើកផ្លូវឲ្យដើរពុំបាន ព្រោះខុសធម្មតាលោក ព្រះរាមត្រាស់ឲ្យពញានលជាមេការចងថ្នល់ ឆ្លងមហាសមុទ្រ ហើយព្រះរាមត្រាស់ឲ្យលើកទ័ពទៅដល់ក្រុង

លង្កា រាជនិងទសកណ្ឌ ក៏បាត់បាហានឲ្យឈប់មើលទៀត ពួកអ្នកឈ្លប ស៊ើបការណ៍ទាំងនោះមកឃើញក៏សរសើរព្រះរាមនូវពួកពានរទាំងអស់ ក្រុងរាពណ៍ឡើងលើប៉មថ្កោលមើលពលទានរ ហើយឲ្យរៀបធ្វើភ្ជុំមិត្រជា ព្រះសីតព្រះរាម ដើម្បីបញ្ឆោតនាងសីតាថា ព្រះរាមស្លាប់ ហើយ តែនាងត្រីជាដាទូលសេចក្តីពិតឲ្យនាងសីតាស្តាប់ ទើបស្រាយសោក ព្រះបាទមាលិយវង្សជាជីតាបានដាស់តឿន ក្រុងរាពណ៍ឲ្យបញ្ជូននាងសីតាទៅវិញ ព្រោះខុសគន្លងធម៌ តែក្រុងរាពណ៍មិនព្រមបញ្ជូន ពិភេកសណ៍ប្រើ សេនាទាំង ៤ មកស៊ើបក្នុងនគរលង្កា ព្រះរាមក៏លើកទ័ពចូលក្រុងលង្កាក្នុងខណៈនោះ ស្តេចឡើងភ្នំសុវេលដើម្បីមើលក្រុងលង្កា ឃើញទសកណ្ឌអង្គុយនៅលើប៉មមានឆត្របាំងនិងតាមរៀបផ្កាត់ សុគ្រីពក្រោធទើបហោះទៅកាច់ឆត្រនិងកន្ត្រាក់យកមកុដចេញពីក្បាលទសកណ្ឌ ហើយច្បាំងគ្នាគគ្រឹមនៃផលកងទ័ពចូលរាយ ៗ ព្រះរាមបានបញ្ជូនអង្គទជាកងទូតទៅចរចាតាមប្រវេណី តែក៏ទៅកើតច្បាំងគ្នានឹងសេនាយក្សមួយពើត ៗ ក្រោយពីនេះទៅក៏និយាយពីការច្បាំងដោយពិស្តារ ពួកយក្សមានពលយុទ្ធប៉ុន្មានថែម ក៏យកមកប្រើតែអស់ ៗ ជាដម្កា ព្រះឯកដែលជាតាយក្រោធ តែឈ្នះសត្រូវជាដរាប រឿងព្រះរាមក៏ដូច្នោះដែរ ព្រះរាមជាទូតមគតិរបស់ពួកហិណ្ឌូ ច្បាំងកាលណាក៏សុទ្ធតែមានជ័យ ៗ ពោះបីពលពានរត្រូវអាវុធធ្លាប់ទៅខ្លះ ក៏ត្រូវជប់រស់ឡើងវិញ ព្រោះ

លក្ខណ៍ត្រូវស្រការណា ក៏មានចាំតែតាន់ ខាងពាក្យរហូតដល់មេទ័ពមេកងស្លាប់ហើយក៏ស្លាប់ពន្លក សូម្បីនាងមណ្ឌោគិរី (មណ្ឌោ) តាមធ្វើពិធីក្បួនថ្នាំមិញកកមក ព្រោះកផែកស្លាប់ហើយឲ្យត្រឡប់រស់មកបញ្ចាំងបាន ក៏ត្រូវហនុមានទៅចំណារពិធីខួបអស់ ១ សុកណាអាចផកជួនចិត្តតាកខ្ទង សត្វាប់មិនស្លាប់ ក៏ត្រូវហនុមានទៅបញ្ចេញយកមកបាន ការបញ្ចាំងគ្រានេះពួកពង្សផង្សញាតិយក្សស្លាប់កលស្មើរផុត ពួកបញ្ចាំងលើកក្រោយបំផុត ព្រះរាមថ្ងៃនេះព្រៃហោស្ត្រត្រូវដើមទ្រូងក្រុងរាពណ៍ ផែកជា ២ ភាគស្លាប់ទៅ ។

ព្រះរាមមិនបានស្តេចចូលក្រុងលង្កាទេ គ្រាន់តែទ្រង់ឲ្យតាក់រំលាយសព្វក្រុងរាពណ៍ហើយ ឲ្យរៀបជាភិសេកពិភេកសណ៍ជាព្រះជាក្រុងនគរលង្កា ឲ្យព្រះលក្ស្មណ៍ចូលទៅស្រោចទឹកសិទ្ធ ត្រាស់ឲ្យពិភេកសណ៍នាំញញឹមនាងសីតាមកគាល់នៅព្រះពន្លា តែព្រះរាមមិនព្រមទទួលនាងសីតា ទើបគោរពតាក់ផ្សងលុយភ្លើង: ដើម្បីសំដែងសេចក្តីបរិសុទ្ធក្នុងខ្លួននាង ដែលខ្លាក់ក្លាក់ទៅនៅក្នុងកណ្តាប់ដៃយក្ស ពពួកទេវតាមកប្រជុំគ្នាគដើម្បីជាសាក្សី ហើយព្រះរាមសូមពរព្រះឥន្ទ្រ ឲ្យបណ្តាពានរដែលបស្លាប់ហើយក្នុងសមរភូមិត្រឡប់រស់ឡើងវិញ ។

លុះដល់វេលាដ៏សមគួរ ព្រះរាមះស្តេចត្រឡប់មកនគរស្រីអយុធ្យា ពិភេកសណ៍នាំបុស្បកមកថ្វាយឲ្យគង់ នឹងប្រាប់ដំណើរដល់ស្តេចនេ·

ស្ដេចគុហៈដែលជាមេខ្មាន់នៃពួកនេសាទនៅស្រុកស្រឹង្គវេរ ឲ្យហ៊ុំមាន
ទៅគាល់ព្រះភរតៈទូលដំណឹង ព្រះភរតៈទ្រង់ព្រះសព្រះរយ៍ទើបប្រុងប្រៀប
រៀបផ្លូវថ្វាយទ័ពក្បួនហែ. នាងកៅសល្យា សុមិត្រាទាំងនាងកៃកេយី
ចេញមកទទួលព្រះរាមដល់ឧទ្ទិត្រាម. ព្រះរាមស្ដេចចូលបាក្រុងស្រី
អយុធ្យា ត្រាស់ឲ្យចាត់ការកាត់សក់សេកកាមកជប្រេះណើ កជាសុខដាននឹង
ស្ដេចពាន់ឈ្នះពួកទូលលាត្រឡប់ខៃកើសក់ង្គ ពជាពក់កេសណ៍ទូល
លាទៅនគរលង្កាវិញ ទ្រង់តាំងព្រះលក្ស្មណ៍ជាមហាឧបរាជ តែមិនព្រម
ទទួលដំណែងនោះ ទើបបានទៅព្រះភរតៈ ព្រះរាមទ្រង់ធ្វើពិធីផ្សេងៗ
សម្រាប់ក្សត្រគ្រងរាជ្យនៅមួយម៉ឺនឆ្នាំ មានទាសទាំងពាន់ទ្រង់ធ្វើពិធី
អស្វមេធដល់ទៅ ១០ដង ស្រុកទេសរះនៅជាសុខសប្បាយ រាជត្រកូល
កំរុងរឿងកណ្ណាប្រជាជនតាំងនៅក្នុងសីលធម៌ ។

ឧទាហរណ៍អភិតារៈក្នុងរឿងរាមកេរ្តិ៍មាននៅជាច្រើនអន្លើដូចយ៉ាង:

ក - គ្រាក្រោបនន្ទុក ព្រះឥសូរក៏មានទេវទត្តាឲ្យព្រះនារាយណ៍
មកក្រាប តានេះបានបែងកាយជាស្រ្ដីមកបញ្ឆោតឲ្យនន្ទុកភ័ក្ដ្រាម ។

ខ — គ្រាព្រះឥសូរប្រទាននាងឧមាដល់ទសកណ្ឋ ពួកទេវតានិករ
ភ្ញើលជ្រួលច្រើម ទើបនាំគ្នាទៅទូលព្រះនារាយណ៍ ៗ ក៏ហោះមកកាន់ទី
ដើមផ្លូវទៅលង្កា នៃស្ដេចមកប្រែកាយជាយក្សចាស់ កំពុងដាំដើម
ឈើយកចុងចុះក្រោម យកគល់ឡើងលើ ទសកណ្ឋឃើញចម្លែក

គឺស្មាថាអាយក្សនេះឆ្កួតទេឬអ្វី បានជាងាំដើមឈើយកចុងចុះក្រោម ។ ព្រះនាកយណ៍តបថា អ្នកឯងថាតែយើងឆ្កួត ត្រង់អ្នកឯងយកស្រីកាឡកណ្ណី ទៅធ្វើជាប្រពន្ធមិនមែនឆ្កួតទេឬ? យើងប្រាប់ឲ្យបានដឹង ស្រីនេះជាស្រីចៅស្រែគាឡកណ្ណី តែងយកទៅដឹងបំផ្លាញុះសុវណ្ណយក្សក្រុងលង្កា ទិនសាបសូន្យ ហើយតែងនាំឲ្យផ្លាស់យកនាងមរណ្ណា មកវិញ ។

គ.- គ្រាព្រះនាកយណ៍ផាសរ បានដល់កាលត្រីបុរីមិនវែងថ្ងៃ ក្រុកនិទទៅតាមគូតដល់ជាទ់កម៉ែរុំ ព្រះឥស្សរក្រាបបំភ្លុកគោ១សត្វកាដ ឲ្យជាន់ ទិនចាប់យកនាកយណ៍ ផែកជាសរមកបាញ់ឆាងចំពុំរបរដ្ឋ ក៏ចំលាក់សូរពោះ ព្រះនាកយណ៍កើនបន្ទូលស្ដីទូលថា ព្រះឥន្ទ្រហាមមិនឲ្យខ្ញុំសម្លាប់ត្រីបុរីម៉ ទើបខ្ញុំដែកលាក់ទៅ សូមព្រះឥន្ទ្រជាអង្គា បំណោកអភ័យទោស ។

គ្រានេះ ក្នុងរឿងនាកយណ៍សំបុត្ររបស់សៀមបែបចាស់ ចាត់ជាគ្រាទី ១០ គអំពីអបក្រវិតារ ដែលព្រះនាកយណ៍មែន ជាជាងអប្បទៅក្រោមបនទូក សង់គ្នានូករឿងនាកយណ៍សំបុត្រលិលិត របស់ព្រះបាទសម្ដេចព្រះមហាវជិរវុធ ។ ក្នុងរឿងកម្ពុជាជិតនឹងផ្សព្វផ្សាយ ទី ១ ពោលថា មុខដែលទី២ដល់ពីអាវតារនេះ ព្រះនាកយណ៍បានបែងកាត់មកដល់ទៅ ៩ ជនដូច្នេះ គ្រានេះទើបចាត់ជាគ្រាទី ១០ ។

អ្នកប្រវត្តិសាស្ត្រសង្កេតថា ការបញ្ច្រាមនោះគឺបច្ចុប្បន្នគានូវវេន

មនុស្សនឹងមនុស្សផងគ្នា មិនមែនជាយក្សជុះពង្គម ដូចរូបគំនូរនោះទេ ព្រោះព្រះរាមនឹងពួកអយោធ្យា គឺជាពួកមនុស្ស សម្បុរសជ្រះ ដែលហៅថា អារ្យៈ, ពានរគឺជាពួកមនុស្សដែលនៅតាមជួរភ្នំវិន្ធ្យ សម្បុរខ្មៅ, សក់ក្រញាញ់, បបូរមាត់ក្រាស់ជិតទៅខាងនោះ ក្នុងសម័យដែលពួកអារ្យៈលើកគ្នាមកអាស្រ័យក្នុងបរិវេណជួរភ្នំនេះ ក៏បែងចែកដីជាចំណែកៗដែលគ្នាគ្រប់គ្រង ការចិញ្ចឹមរបស់ពួកស្រុកដោយបើនវាទិយម ក្នុងការធ្វើស្រែ ការពង្រីកគ្នា ចេះមិនសូវបានញឹកញយ, វណ្ណៈក្សត្រមាន ការធ្វើអ្នកចំបាំងដោយត្រង់ជាអ្នករួមកិច្ចជាមួយម្ចាស់ផែនដី ដែលហៅថា ពង្សទ្យ បានទទួលប្រយោជន៍អំពីម្ចាស់ផែនដីជាច្រើន មិនបាច់ធ្វើការកែស្រូវខ្លួនឯង ការស្រែធ្វើមកមានធ្វើខ្លះជាមួយពង្សទ្យ, ពួកអារ្យៈគង់សន្សំផ្សាយចេញមកខាងត្បូង ដោយហេតុដែលខ្លួនបានបំបែកវង្សរៀងមកហើយ ទើបអាចគ្រប់គ្រងផែនដីឆ្ងាយទៅទន្លេដេកខិន (ទក្ខិណាបថ) បានជាប្រយោជន៍ក្នុងការធ្វើសង្គ្រាមច្បាំងដល់បានទៅដល់កោះលង្កា ដែលជាទីលំនៅរបស់ជនមួយពួក សិងសម្បុរខ្មៅ សក់ក្រញាញ់កង កាយធំៗ ដែលយាងមនុស្សក្នុងទ្វីបអាហ្វ្រិក, ពួកអារ្យៈសម្បពួកនេះទើបហៅថា រាក្សសៈឬយក្សបានធ្វើសង្គ្រាមគ្នាកាន់ធំៗ ការដែលត្រូវពពណ៌លួចនាងសីតានោះ គង់ដោយហេតុអ្នកឃើញនាងល្អ ក៏ជាប់ចិត្តស្រឡាញ់ចង់បានធ្វើជាមហេសី គ្មានអ្វីដែលនឹងយកឲ្យបានក្រៅ

អំពីគិតល្អ ក្នុងពេលដែលពួកកោរព្យៈធ្វេស ក្នុងទីបំផុតក៏កើតជា ចំបាំងទៀត ដ៏ជាហេតុឲ្យឫស៊ីឈ្មោះវាល្មិគី និពន្ធមហាកាព្យហៅ ថារាមាយណៈ ក៏ជារឿងមហាសង្គ្រាម ជាគូគ្នានឹងរឿងមហាភារតៈ ។

ក្រឹស្ណាវតារ រឿងនេះមានអ្នកនិយាយតែងជាច្រើន ហើយក៏មានរឿង រាយរងស្ទើរតែរាប់ពុំអស់ ពួកព្រាហ្មណ៍ជាន់ក្រោយ ៗ ក៏និយមថា ព្រះ ក្រឹស្ណៈនេះជាតួព្រះនារាយណ៍តែម្តង ទើបគាត់ថា អ្នកណាបានតែងរឿង សរសើរកិត្តិយសនឹងបានបុណ្យកុសល, អ្នកប្រាជ្ញអឺរុបសន្និដ្ឋានថា សេចក្តីពិតព្រះក្រឹស្ណៈជាក្សត្រធម្មតានេះឯង តែក្លាសក្នុងកលយុទ្ធ និងប៉ូល ចិត្តធ្វើសង្គ្រាម ទាល់តែបានជាមហាអំណាច, ព្រះបាទសម្តេចព្រះបរមា- វិកវុធថា ព្រះក្រឹស្ណៈជាបុរសក្លាហាន មានសតិបញ្ញាអង់អាចច្រើនក៏ ពិត តែសេចក្តីប្រព្រឹត្តច្រើនថោកទាប មានកិលេសខ្លាំងក្លា អ្នកណាធ្វើ ឲ្យឈឺចិត្តក៏សម្លាប់ចោលងាយៗ ទាំងចូលចិត្តប្រព្រឹត្តក្នុងផ្លូវកាមេសុ- មិច្ឆាចារ ជាអ្នកប្រើកលល្បិចនឹងមាយាប្រាសចាកធម៌, តែក្នុងការល្អ ប្រពន្ធ ទក្កា យាគកម្ម ពួកអ្នកតែងរឿងព្រះក្រឹស្ណៈតែងលើកជាសរសើរ ទៅលើគុណសម្បត្តិ សឹងធ្វើឲ្យឃើញច្បាស់ថា សាសនាព្រាហ្មណ៍ក្នុង គ្រានោះបានថយចុះទៅដូចម្តេចខ្លះ និងធ្វើឲ្យឃើញថា ហេតុអ្វី ព្រះពុទ្ធអង្គទើបបញ្ញត្តិសាសនាថ្មី ១ នេះ ក៏ព្រះអង្គមិនឃើញផង ក្នុងគុណសម្បត្តិរបស់ព្រះក្រឹស្ណៈនោះឡើយ ។

រឿងព្រេងក្នុងស្រុកនោះថា ព្រះបាទឧត្តរសេន អ្នកគ្រងនគរមេឃុក មាន មហេសីជាមតេត នាមថា កណ្ណិកល្យា, នាថ្ងៃមួយព្រះស្ដេចទៅប្រពាតព្រៃ ក៏ទ្រង់ទៅអំពីពួកនាងកញ្ញា អ្នកស្រុកមួយបានឃើញនាងក៏ជាប់ចិត្ត ទើបបំណែងកាយជាព្រះស្វាមីរបស់នាង ហើយទៅរួមសំវាសផង លុះមក នាងទ្រង់គភ៌ប្រសូតបុត្រមកឲ្យនាមថា "កន្សរ" ជាមនុស្សកំណាចបរិបូរ រួស លុះធំឡើងសំដែងសេចក្ដីវិលវល់ឃើញថា ការគោរពព្រះកម៌នោះមិនជាការសមគួរ ព្រោះជាក្សត្រដូចគ្នា ព្រះបិតាទទឹងទាស់ ព្រះកន្សរក្រោធទើបដកព្រះបិតាចេញចាកជសម្បត្តិ ឡើងគ្រងរាជ្យដោយខ្លួនឯង ប្រកាសឲ្យគោរពបូជាព្រះសិវៈ មហាទេពជំនួសព្រះពុទ្ធ ព្រះកន្សរធ្វើសង្គ្រុបសង្កិនពួកស្ត្រីដែលមិនជឿតាមឲ្យបានក្ដៅក្រហាយ, ព្រះធរណីទើបជំណែងខ្លួនជាគាវីទៅទូលរឿងនោះដល់ព្រះឥន្ទ្រព្រមទាំងទេពឯទៀតក៏នាំគ្នាទៅទូលដែរ ព្រះឥន្ទ្រឃើញសមគួរនឹងគ្រោងបណ្ដាលនេះ ទើបអញ្ជើញព្រះនារាយណ៍ឲ្យអវតារមកកើតជាបុត្រស្រីព្រះវាសុទេពក្សត្របត្រូវង្ស ។

នាថ្ងៃមួយក្នុងខណៈដែលស្ដេចកំពុងប្រពាតព្រៃ ស្រាប់តែឮសូរសំឡេងអំពីអាកាសមកថា បុត្រទីប្រាំបីរបស់ព្រះវាសុទេពនឹងសម្លាប់ព្រះអង្គ ព្រះកន្សរក្រោធណាស់ក៏ចាប់ជាប់ឃុំព្រះវាសុទេព តែនាងសុំជីវិតទុក ហើយសន្យាថា បើនាងប្រសូតបុត្រពេលណា នឹងបញ្ជូនមកឲ្យសម្លាប់វេលា

នោះ ព្រះវិស្ណុប្រាប់រឿងនេះហើយ ទើបឲ្យយោគនិទ្រាទៅទទួលយកកូន ហិរណ្យកសិបុ មកយកកំណើតក្នុងគភ៌នាងទេវកី ចំនួន ៦ អង្គ ដើម្បីឲ្យ ព្រះកង្សសម្លាប់ ឲ្យសេសនាគទៅកើតជាកូនទី ៧ តែលុះកើតមកឲ្យទទួល យកទៅបញ្ចូលក្នុងគភ៌នាងរោហិណីទៅវិញ ដើម្បីនឹងបានជួយព្រះ នារាយណ៍កម្ចាត់អសុរ សេសនាគនេះគឺព្រះពលរាម, ឯព្រះវិស្ណុនោះទ្រង់ អវតារមកជាអង្គទី ៨ វេលាប្រសូតឲ្យព្រះវាសុទេពនាំទៅបញ្ចូលក្នុងគភ៌ នាងយសោទា ហើយផ្ទេរមកបញ្ចូលក្នុងគភ៌នាងទេវកីឲ្យព្រះកង្សសម្លាប់ ជំនួស, ទាល់ព្រះកង្សជ្រាបថា ទារកនោះប្រសូតក៏ម្ញាមកចាប់ទារក នោះបោកនឹងផែនសិលា. តែទារកនោះសំដែងឫទ្ធិហោះទៅកាន់វេហាស៍ ស្រែកថាព្រះវិរេជកើតហើយ នឹងចំផ្លាញអាឯងជាប្រាកដ ។ ព្រះកង្ស បានឮដូច្នោះ ក៏តាស់ចិត្តក្រពេក ទើបបង្គាប់សេនាឲ្យចាប់កូនក្មេង សម្លាប់ឲ្យអស់ ព្រះវាសុទេពទើបប្រាប់នាយគោបាលឲ្យនាំនាងយសោទា ព្រះក្ឫស្ណៈ និងនាងរោហិណីពន្លៀតចេញទៅ គអំពីនេះនិយាយអំពីព្រះ ពលរាមនិងព្រះក្ឫស្ណៈ សំដែងតេជានុភាពយ៉ាងធំ ដូចយ៉ាងនាងបូតនា- យក្ខិនីកំណែងខ្លួនជាស្រីមកឲ្យព្រះក្ឫស្ណៈបៅទឹកដោះពិស ព្រះក្ឫស្ណៈ ជញ្ជក់ដោះ ទាល់តែនាងយក្ខិនីក្ខាប់ ក្ឫណាវត៌ាសុរនិម្មិតជាខ្យល់ កំបុតត្បូង មកឆក់យកព្រះក្ឫស្ណៈទៅ ព្រះអង្គសំដែងឫទ្ធិអសុរធ្លាក់ចុះមក ដីស្លាប់ ថ្ងៃមួយបានលួចទឹកដោះឆក ហើយក្ឡាំងទឹកដោះឲ្យបែក

នាងយសោទា ក្រោធ ក៏យកខ្សែចងភ្ជាប់នឹងត្បាល់ តែអាងនោះទប់កំរាំង ព្រះក្រឹស្ណៈពុំបាន ព្រះក្រឹស្ណៈអូសលេងទាល់តែទៅជាប់នៅចន្លោះដើមឈើធំមួយគូ ព្រះក្រឹស្ណៈអូសទៅទៀតទាល់តែរលើងទាំងឫស ទើបមាននាមថា "ទាមោទរ" ។

នៅយមុនា មាននាគឈ្មោះ កាលិយៈ មានពិសខ្លាំងណាស់ ពួកមនុស្សជិតនោះខ្លាចរអារអ៊ើម ព្រះក្រឹស្ណៈបានទៅតស៊ូតតទង់សម្លាប់នាគនោះ តែពួកនាគជាបរិពារបានសុំជីវិតទុក ទើបបំបរបង់ចេញពីទីនោះ ។

ព្រះក្រឹស្ណៈពួលចិត្តក្លែងលេងនឹង នាងគោបី (នាងគង្វាលគោ) កាលនាងចុះងូតទឹក ស្រាតសំពត់ទុកលើគោក ព្រះក្រឹស្ណៈក៏លបយកសំពត់ទៅលាក់ទុកលើចុងឈើ ដើម្បីមើលពួកនាងស្លៀកទិគម្ពរ (គឺស្រាត) ហើយសើចលេង ។ តមកកើតព្រះហឫទ័យគិតចង់លុបធ្វើទំនៀមព្រះឥន្ទ្រ ទើបនាំគ្នាលើកលែងធ្វើពលិយញ្ញកម្មថ្វាយព្រះឥន្ទ្រ ឲ្យមកគ្នាធ្វើពលីកម្មគោវធនវិញ ហើយខ្លួនក៏យកគ្រឿងសក្ការបូជាល្បោះបរិភោគឯងអស់, ព្រះឥន្ទ្រក្រោធបណ្ដាលភ្លៀងឲ្យធ្លាក់ចុះលិចបំផ្លាញគោទាំងនោះ តែព្រះក្រឹស្ណៈលើកយកភ្នំគោវធនៈមកបាំងការពារទឹកភ្លៀង ទើបមាននាមថា គោវិន្ទៈ (ជាធំជាងគោ) ព្រះឥន្ទ្រពេញព្រះហឫទ័យ ទើបប្រទាននាមថា ឧបេន្ទ្រ (ជាប្អូនព្រះឥន្ទ្រ) ។

លុះធំឡើងក៏បាននាងគោបុរ ៧-៨ នាក់ជាភរិយា ទិយេមការបម្រើ ចិន
ប៉ុន្តែគង់ឥតមានបុត្រ ដែលណាក៏ខ្លួនបានជាច្រើនវែង ដូចយ៉ាងនាមួយនោះ
នាងភាគភរិយាកាយ៉ាករយោង ទូលថា ស្វាមីគាត់ប្រថ្លូណាស់ ព្រះ
កុស្សៈហើយដំណែងខ្លួនជាព្រះភាល័ទ្ធ ខាងភាគសំពះអាយ៉ាករយោងហើយ
បាក់សង្ស័យ ។ ព្រះឥន្ទ្រជ្រាបក៏ប្រញាប់ស្តេចភ្ញាំងភ្ញាក់របស់ព្រះកុស្សៈ
ហើយប្រែអស្សុមកកទ្រោប អស្តុដំណាងកាយជាក្បុសគៈ (គោ) ក៏ត្រូវ
ព្រះកុស្សៈបាប់កាត់សម្លាប់ទៅ, ប្រស្រប្លុះទៀតដំណែងខ្លួនជាសេះគេសិន
ក៏ត្រូវស្លាប់ដូចគ្នា ព្រះឥន្ទ្រហើយនឹងប្លាយឲ្យអគ្គរុះទៅអញ្ជើញព្រះកុស្សៈ
និងព្រះពលទេពមកកើតក្នុងផ្ទៃគ្នា កុមារទាំងពីរមកប្រមឹះទីដូបុស
អ្នកបោកសំពត់របស់ព្រះឥន្ទ្រ ក៏ឲ្យយាយស៊ុំ បុរសនោះតបថា អ្នកណា
ស្មៀកសំពត់រួមជាមួយព្រះឥន្ទ្រនឹងរលាំនូវសេចក្តីវិនាស កុមារទាំងពីរ
ក្រោធក៏ចាត់ជាក់បុរសបោកសំពត់នឹងបើមកាត់ជាប្រលាក់ខ្លាយ រើស
យកតែល្អៗ តែងខ្លួនក្លាយទៅក្រុងប៉ុក ប្រទះអ្នកលក់ផ្កា យកផ្កា
បាយ, កមកដូចនាងឥបយោង កុមារាក្បៀតការក្រាងផ្កា ហួលទៅកង
ក៏ង នាងបានវិលកញ្ចប់ផ្កាយ៉ូវ ព្រះកុស្សៈហើយក្រសិទ្ធីភាពឲ្យខ្លួនក្រង់
មានឲ្ធព្រាយក្បាលម្យ៉ាង ហើយអញ្ជើញព្រះកុមារទៅផ្ទះ ព្រះកុស្សៈ
ក៏ស្ងប់ចិត្តនាង ក្រោកឡើងស្តេចទៅរួចស្តាច ដំបូងបានទៅលេងនឹងអ្នក
ប្រដាល់ម្នាក់មានជ័យជំនះ ព្រះឥន្ទ្រក្រោធបានឲ្យដំរីក្បាលប្រែងលេញជាក់

ព្រះកុម្ភណ្ណៈក៏សម្លាប់ដំរីនោះទៅទៀត ព្រះកន្សែងទើបបង្គាប់ទាហានឲ្យព្រួតគ្នាសម្លាប់ព្រះកុម្ភណ្ណៈលើកឡើងលើព្រះពន្លា សម្លាប់ព្រះកន្សែង ហើយឲ្យទៅអញ្ជើញព្រះបាទឧត្តរសេន ជាជនកព្រះកន្សែងមកសោយរាជ្យជួបដើមព្រះបាទជាកសត្រព្រះរាជាខត្តមេគធា លើកទ័ពមកសង្គ្រាមជំរុំបព្រះកន្សែងតែក៏ចាញ់ទៅទៀត កាលព្រៃនលើកទ័ពមកទៀត តែព្រះកុម្ភណ្ណៈឃើញមជ្ឈកជាក្រុងធំ ពិបាកនឹងវាយក្បាលឲ្យគន់ ទើបទៅឯរោងវាយក្នុងក្រុងនេះក្រុងក្រុងផែកស្តីឲ្យឈ្មោះថា ទូរគា,កាលព្រៃនលើកទ័ពតាមច្បាំងទៀត ព្រះកុម្ភណ្ណៈក្បួនធ្វើជាចាញ់រត់ទៅពួនខ្លះនៅក្នុងគុហា ដែលនៅមាត់ទ្វារមានមតុក្កណ្ឌអ្នកណាប៉ះពាល់ត្រូវក៏កើតជាគ្រូនឆេះស្លាប់ កាលព្រៃនមិនដឹង ចូលវាត្របទះនឹងមតុក្កណ្ឌ គ្រូនក៏ឆេះស្លាប់ទៅ ។ ទ្រង់ជ្រាបកិត្តិសព្ទល្បីអធោមរបស់នាង រាមិណាផ្កាធីតាព្រះបាទកស្សកៈ កើតសេចក្តីស្នេហាទើបឲ្យទៅដណ្តឹង តែនាងបដិសេធ ហើយបានទទួលស្រឡាញ់សិស្សបាលធំជាញាតិរបស់ព្រះកុម្ភណ្ណៈ ។ ភ្លាល់ទើបទៅលួចយកនាងមក អ្នកខាងលើកទ័ពតាម តែច្បាំងចាញ់ព្រះកុម្ភណ្ណៈ ។

ថ្ងៃមួយសទ្រាជិតមកកព្រះកុម្ភណ្ណៈ តែតិតក្រុងត្រូវព្រះកុម្ភណ្ណៈដណ្តើមយកកែវរៀសសាទៅ[១] ទើបយកកែវទៅប្តូរនឹងប្រាសេះខ្មៅមួយ ជា

---

១ កែវលោកខ្មែរ: អាចចណ្តាលឲ្យអ្នកម្ចាស់បានហោះ ក្នុង១ថ្ងៃ ៨ ហាប មឹងការនៃប្រទ្ទីលទៃគ្រឿងគ្រួ បាន ។

មនុស្សមានបុណ្យធ្ងន់ ទៅដើរព្រៃត្រូវកពស់ហែបខាំស្លាប់ ហើយពាំយកទាំងកែវវិសេសនោះទៅផង ពស់ហែបមកប្រែខ្លួនជាស្តេចខ្មាឃុំ បានកើតគស្មិត ខ្មាឃុំឈ្មោះនាំកែវយកទៅ បណ្តាញាតិគិតស្មានថាព្រះកឬស្ណៈប្រទុសកាយប្រសេន ព្រះកឬស្ណៈទើបនាំបរិវារទៅពិនិត្យមើលហើយតាមរកកែវសមន្តកៈ ទាល់តែប្រទះនឹងខ្មាឃុំបានគស្មិត ខ្មាឃុំញ៉មចាញ់លើកនាងជាម្តាតើឲ្យជាជាយា នាំកែវមកប្រគល់សត្រាជិត ១ ក៏ថ្វាយនាងសត្យភាមាឲ្យជាភ្ជាប់ទៀត, រឿងនេះក្សត្រសតធន្វមិនគាប់ចិត្ត ហេតុនេះមកក្នុងថ្ងៃមួយខណៈដែលព្រះសត្រាជិតផ្ទំស្រួល ទើបលបចូលទៅក្នុងវាំងសម្លាប់ហើយលួចយកកែវទៅ គោរព្រោះដល់ព្រះកឬស្ណៈនឹងព្រះពលទេពចេញតាមរក សតធន្វទើបយកកែវទៅផ្ញើនឹងអក្រូរៈ កាលបើជួបចុះ ទាះបីសម្លាប់សតធន្វបាន ក៏មិនបានកែវមកវិញ លុះត្រឡប់មក ទើបឃើញនៅនឹងបងគឺអក្រូរៈ គេរឿងថាលាក់ទុក ព្រះពលទេពក្រោធនឹងព្រះកឬស្ណៈក៏ចេញទៅនៅនគរមិថិលា ក្នុងទីបំផុតអក្រូរៈមកចូលសេចក្តីពិតឲ្យជ្រាប ហើយនាំទៅសត្យភាមាប្រគល់កែវឲ្យអក្រូរៈ ព្រះពលទេពទើបត្រឡប់មកនៅនឹងព្រះកឬស្ណៈវិញ ។

ក្នុងកាលដែលព្រះកឬស្ណៈផ្ចាញ់ព្រះឧតរមោឃ នរកាសូរបានមកបៀតបៀនពួកទេវតាពីកា ដែលពុតិមកកើតជាចិតាកក្រ ទាំងភិតលោកចង់ដានដំរែឯកវិណាផង គម្រាមថាបើព្រះឥន្ទ្រមិនឲ្យនឹងលើកទ័ពទៅកយ ព្រះ

អង្គរកាន់អន្ទះព្រះក្រឹស្នៈឲ្យចាត់ការកម្រើប ព្រះក្រឹស្នៈបានជួយពួកនាងនារីចំនួនមួយម៉ឺនប្រាំមួយពាន់ឲ្យរួចពីការគ្រោះថ្នាក់ ហើយលែងគេចូលរួមសំណាក់ទីលំនៅផ្ទាល់របស់ព្រះអង្គ ក្នុងខណៈនោះប្រាកដថា ព្រះក្រឹស្នៈមានជាយាតស់ទៅមួយម៉ឺនប្រាំមួយពាន់ ព្រះអង្គមានសេចក្ដីពេញចិត្តណាស់ ពេញព្រះក្រឹស្នៈណាស់ហើយ ។ នាងសត្យភាមានោះមានសេចក្ដីលោភលន់ក្រៃពេក កាលបានឃើញដើមបារិជាតិព្រឹក្សក៏ចង់បាន ប្រាប់ឲ្យព្រះស្វាមីយកចុះមកមនុស្សលោក ព្រះអង្គឃើញព្រះក្រឹស្នៈធ្វើដោយអំណាច ក៏ចុះមកដណ្ដើមយកទៅវិញ តែក៏បាញ់ ។

គម្ពីរមហាភារតៈពោលថា បុរាណជាតិត្រកូលក្សត្រយ៉ាណ្ឌព កាលដែលធ្វើពិធីសួយម្ពរនាងទ្រុបទី (ទ្រោបទី) បានសម្រេចថា នាងត្រូវជារបស់ព្រះអជុន ព្រោះតែក្រោះនោះ ព្រះអង្គនឹងព្រះអជុនបានទៅជួយលត់ភ្លើងនៃព្រៃព្រះអង្គបានចក្រកាលខ្សែក្រៀងជាប់ជួយលត់ ព្រះក្រឹស្នៈនឹងព្រះអជុនរួមកំឡាំងគ្នាលត់ពាលនៃសម្រេច ព្រះអង្គពេញព្រះហឫទ័យទើបប្រទាន ១- ចក្រវែងនាក ២- គទាកៅមោទក, ៣- ស័ង្ខបញ្ចជន្យ: ។

មួយទៀត កាលព្រះយុធិស្ឋិរប្រកាសធ្វើពិធីរាជសូយៈតំពិធីប្រកាសសេចក្ដីជាធំចំបង គ្រានោះមានក្សត្រ ១០១ មកជួយផ្ទុះចូលក្រោមខៈ សិសុបាលបាននិយាយសើកសៀតឲ្យព្រះក្រឹស្នៈក្រោធ ក៏ទាល់ចក្រទៅ

កាត់ក្បាលសំរុបាលស្លាប់ទៅ  កងត្រៃលេងភាស្កាក្លា រកងក្សត្រិយ៍បា-
ណ្ឌពទីរគោរព  ពួកបាណ្ឌពជាម្ចាស់បាញ់  គេងលើកនាងគួស្អាឲ្យជា
ទាសី នាងត្រូវអស់ទាល់រស់ពត់អាក្រាតអស់អំពីខ្លួន តែបារបានព្រះ
គ្រសួនរិមិត្រកាយជាសំពត់ទៅទុកនាំឲ្យ ហើយ ផុតអំពីសេចក្តីអាមាសមុខ
កងមហាការយុទ្ធចំបាំងរកង់ក្សត្រិយ៍បាណ្ឌពទីរគោរព  ដែលជាបងប្អូន
នឹងគ្នា ព្រះគ្រសួនទៅឃាត់សឹក តែមិនស្តាប់ ហើយ រមិត្រកាយជាពាហើម·
រថសឹករថសព្រះអរជុន  ឯកំឡាំងនោះបានបែកលែងយុទ្ធសិល្ប៍  ប្រាប់
បាយឲ្យក្សត្រិយ៍បាណ្ឌពចប់ង បាណ្ឌពក៏បានជ័យជំនះ ។

ព្រះគ្រសួននេះ  សម្បីតែប្រពន្ធសង្សារក៏គេរមិញ មានរឿងថា ព្រះ
គ្រសួនមានឱរសឈ្មោះថា ប្រទ្យុម្ន ទៅឈ្មោះអនិរុទ្ធ មានចៅស្រីកាត់ក្រុង
ពាណ  មានសុបិននិមិត្តថា  មានបុរសចូលទៅកន្លែងបន្ទប់របស់នាង
ហើយគេបាត់ទៅ លុះព្រឹកឡើងនាងប្រាប់ក៏កៀងថា បើមិនបានជួបនឹង
បុរសនោះទេ ជីវិតប្រហែលជាគ្មានទេ កៀងជាអ្នកស៊ីល្បិចបានគូរ
រូបភាពបុរសផ្សេងៗដែលសំខាន់ៗបង្ហាញនាងៗស្រឡាញ់រូបអនិរុទ្ធ
កៀងទទួលអាសាទៅយកអនិរុទ្ធឲ្យមកជួបនឹងនាង  ក្រុងពាណប្រាប
រឿងក៏ត្រាចឲ្យទាហានទៅចាប់  អនិរុទ្ធ ទា ពួកគេ ស៊ូបានស្លាប់
ពួកអសុរអស់ទៅហើយ  ក្រុង ពាណាស្វ ត្រាចនាំងណា សំបានរហាល
នាគបាសទៅរួបរឹតព្រះអនិរុទ្ធបានឲ្យយកមក ផ្កា កណ្តាលក្រុង  គិតនឹង

សម្ពាធ, ដោយដល់ព្រះក្ឫស្ណៈ ។ ក៏បបួលព្រះពលទេព[១]មកជួយទៅក្រុងពាណ ក៏ធ្វើពិធីសុំឲ្យព្រះសិវៈមកជួយផង លើកសង្គ្រាមរវាងទេវទាំងព្យូគ្រ តែក្សត្រិយ៍ជាអ្នកមានជ័យ ក្រុងពាណក៏ព្រមលែងអនិរុទ្ធ នឹងលើកនាងឧសាឲ្យ ។

តមកព្រះក្ឫស្ណៈផ្ទុកម្រាប់ត្រកូលយាទវៈ ព្រោះទៅបៀតបៀនឫសីនារទ: ក្នុងចុងបំផុត បងប្អូនកើតបង្កាំងគ្នាឯង ព្រះក្ឫស្ណៈបានតែគង់យ៉ក្រមើលដោយសេចក្ដីតូចចិត្តខ្លួលក្នុងវេលានោះមានព្រានដើរមកតាមផ្លូវនោះ ឃើញគិតស្មានថាជាប្រើស យកធ្នូបាញ់ទៅត្រូវព្រះក្ឫស្ណៈសុគតទៅ ។

រឿងព្រះក្ឫស្ណៈនេះ ក្នុងវណ្ណៗគេកប់គានជារឿងធំប្រហែលៗ គ្នានឹងរាមកេរ្តិ៍ ក្នុងគាស្នាៗយើងក៏មានរឿងទណារុទ (អនិរុទ្ធ) តែ ១ ដែលស្រង់សេចក្ដីពីអវតារត្រានេះ ។

- ពុទ្ធាវតារ ដោយហេតុព្រះពុទ្ធជាអ្នកមានបុណ្យអស្ចារ្យណាស់ផង ដូចឬជាងព្រះអវតាររបស់ព្រាហ្មណ៍ ទាំងមានអ្នកចុះចូលព្រះពុទ្ធសាសនាច្រើនឡើងៗ សាសនាព្រាហ្មណ៍ក៏សឡេមសាបសូន្យទៅ មិនដឹងបើនឹងគិតធ្វើម្ដេចនឹងឲ្យត្រឡប់រុងរឿងវិញបាន ពួកព្រាហ្មណ៍

---

១ ព្រះពលទេពមេដ្ឋាយប្អូនគ្រានេះ មានពិធីធ្វើដំសំរាប់ ។ លក់ពេញព្រះជាម្ចាស់ ឬទានពរឲ្យព្រះធាតុក្នុងពិធីច្រត់ព្រះនង្គ័ល; ក្នុងមីលក្ខណ៍ ព្រះរាជពិធីច្រត់ព្រះនង្គ័ល ដែលឧកញ៉ាខ្ញុំតែងចិងប្រោះពុទ្ធក្នុងឆ្នាំ ១៩៤៤ នោះហើយ ។ (អាទិត)

# ពង្សាវតារប្រទេសចិន

## ហ្វូនទិពន្ធពទ្រ៍ ញ៉ុក-ថៃម វៀចវៀន (តមក)

## អំពីចិន — និងជនល្ងៀ

កាលបើបានប្រាបប្រាមពួកតួកិកងដែលមុំគ្នាលើកបះបោរស្រេចហើយ ទើបព្រះបាទថៃ-សុនមហាកជ ទ្រង់ចាប់ផ្ដើមប្រាបប្រាមពួកតួកិទិសខាងលិចតទៅទៀត ដ្បិតក្នុងសម័យនោះពួកតួកិផ្នែកនេះនៅមានកំឡាំងរឹងប៉ឹងនឹងអំណាចនៅឡើយ ហើយបានគ្រប់គ្រងរហូតទៅដែនដល់បាក-ទ្រៀន ទាំងជាសត្រូវយ៉ាងធំរបស់ប្រទេសពែរ្សផង ។ ព្រះបាទថៃ-សុនមហាកជ ទ្រង់ចាត់ចែងប្រសាសនោបាយយ៉ាងក្បត្រ៉ដែលទ្រង់ឈ្លាសវៃអស្ចារ្យមួយ ៖ គឺនៅវេលាដែលទ្រង់ធ្វើចម្បាំងនឹងពួកតួកិទិសខាងកើតនោះ ព្រះបាទថៃ-សុនមហាកជ ទ្រង់ធ្វើនយោបាយចងស្ពានមេត្រីយ៉ាងជិតស្និទ្ធនឹងពួកតួកិទិសខាងលិច ដើម្បីមិនឲ្យពួកតួកិទិសខាងលិចលើកទ័ពទៅជួយពួកតួកិទិសខាងកើតបាន ប៉ុន្តែកាលដែលទ្រង់បានប្រាបប្រាមពួកតួកិទិសខាងកើតកបពាបអស់ហើយ ។ ទើបព្រះបាទថៃ-សុនមហាកជ ងាកទៅរកវៀងពួកតួកិទិសខាងលិចវិញ គាប់ចួនជាមានហេតុទាស់ទែងគ្នាកើតឡើង គឺកាលពីពុទ្ធសករាជ ១១៨៤ នោះ ពួកទាហានពួកតួកិទិសខាងលិច លើកចូលមកប្រទូសរ៉ាយពួកចិននៅប្រទល់ដែន ទើបព្រះបាទថៃ-សុនមហាកជ ទ្រង់ឲ្យលើកទ័ពទៅច្បាំង

ប្រុបប្រាមព័យទ ទ្រានចូលការ ហេតុ ដល់ទន្លេ ខណ្ឌ ប្រទេសឥណ្ឌា
តាំងតែក្រុងត្រៃភ្នំ មួយអង្គនៃនគរទាទទួលរាប់រងអំណាចរបស់ចិន
(ប្រទេសកម្ពុជា ត្រឹមបណ្ដាការ) កាលពីពុទ្ធសករាជ ១១៨៥. ។
តាំងអំពីនោះមក ប្រទេសឥណ្ឌា ក៏កោតខ្លាចអំណាចព្រះបាទថៃ—សុង
នៅក្នុងសំណាក់ធំ ។ ក្នុងឥណ្ឌា ក៏តាំងទាំងនាំគ្នាមកចងស្ពានមេត្រីនឹងចិន ។
ក្នុងឆ្នាំពុទ្ធសករាជ ១១៩៤ ព្រះបាទសីលាទិត្យ ជាមហាក្សត្រសំខាន់
មួយអង្គរបស់ឥណ្ឌា ដូចមានទេញព្រះនាមក្នុង ប្រវត្តិសាស្ត្រ ស្ដេចឥណ្ឌា បាន
ចាត់ការទទួលអ្នកជំនួញចិន ២ នាក់ ឈ្មោះលី - អ៊ី ប៉ៅ និងវ៉ាង -- យួនសេ
ហើយបានចងផ្ញើស្ពានមេត្រីនឹងព្រះចៅក្រុងចិនក្នុងគ្រានោះតមក ៣ ឆ្នាំ
ទៀត វ៉ាងយួនសេ បានចូលមកឥណ្ឌាម្ដងទៀត តែវេលានោះព្រះបាទ
សីលាទិត្យ ទិវង្គតទៅហើយ ព្រះកជាអរជុន: បានគ្រប់គ្រងកងសម្បត្តិ
ជាតំណតមក បានកាត់ស្ពានមេត្រីនឹងចិន មិនត្រឹមតែមិនទទួលកងទូត
ចិនប៉ុណ្ណោះទេ ថែមទាំងឲ្យទាហានមកប្លន់កងទូតចិនទៀតផង វ៉ាង—
យួនសេ គេចរត់ពីសេចក្ដីអន្តរាយទៅបានប្រទេសប្រជិយ ហើយបានទៅ
សុំកំឡាំងកងទ័ពរបស់ព្រះចៅនៃតំបន់ប្រទេសទីបេតនិងព្រះកជាប្រទេស
នេប៉ាល ប្រទេសទាំង ២ នេះទទួលរាប់រងអំណាចចិន វ៉ាង — យួនសេ
នាំទាហានទ្រានចូលដល់ក្រុងកនូជ ហើយចាប់ព្រះកជាអរជុនចង
ច្រវាក់នាំខ្លួនទៅក្រុងស៊ី — អាន កាលពីពុទ្ធសករាជ ១១៩៤ ។

# អំពីគុណករសម្បត្តិរបស់ថៃ – សុង

មកដល់ខណៈនេះ ព្រះបាទថៃ – សុងមហារាជមានព្រះជន្មកុដល់ ៥៤ ព្រះវស្សា ឯណី – បណ្ដោះព្រះរាជបិតាទិវង្គតទៅ ហើយតាំងអំពីគ្រាណាមិនប្រាកដ ព្រះបាទថៃ – សុងជាព្រះមហាក្សត្រធំបំផុតក្នុងលោក ក្នុងសម័យរបស់ព្រះអង្គទ្រង់រាប់ជាផាកាលេកត្រូវ៍ ប្ដីណាក៏ចូលមករបស់ទីបការសុំបាន តាំងអំពីប៉ុកណាកាលរហូតមកដល់សម័យ ព្រះបាទថៃ-សុងមហារាជនោះ ... លេក្សត្រមហារាជចេញហើយ មិនមានមហាក្សត្រាត្តិណាមានបុណ្យសក្តិនិងឫទ្ធិអំណាច ប្រហាលនឹងថៃ - សុងមហារាជឡើយ ។ ប្រទេសចិនក្នុងសម័យរបស់ព្រះអង្គជាប្រទេសដែលវត្តធំខ្ពស់បំផុតក្នុងលោក ។ ព្រះបាទថៃ - សុងមហា-រាជនោះ ទ្រង់សរសេរសៀវភៅរបស់ព្រះអង្គមួយអម្ពីថា " ពួកដែលធ្លាប់ធ្វើការប្រាប់ប្រាប់ពួកមនុស្សព្រៃមកហើយ (អ្នកអានប្រកែកស្រ្តីចិនក៏ក្លែបថា ចិន ហៅជនជាតិតាំងប្រទេសក្រៅពីចិនថាជា "មនុស្សព្រៃ" ជាដរាប ព្រោះគេយល់ថាជាតិដទៃមិនចំរើនស្មើនឹងចិនទេ.) មានតែ ២ នាក់ទេ គឺយុំង-ចក្រពត្តិរដ្ឋផិន (ចិន-ហ្ស៊ីន) ១ រូប- ទីក្នុងរាជវង្សហ័ន ១ តែការដែលយើងចាប់បានយើងឡើង យើងអាចធ្វើការប្រាប់ប្រាមបាន ២០ ... ធ្វើឲ្យសមុទ្រទាំង ៤ ទិសស្ងប់ស្ងាត់ មនុស្សព្រៃទាំងឡាយនៅដែនឆ្ងាយ ១ ជាចស្រយាល ដើររៀងគ្នា

ចូលមកថ្វាយខ្លួនធ្វើជាខ្ញុំយើង" ។ លី-តៃប៉ោ ក៏រឹងករបស់ចិនម្នាក់ពោលទុកអំពីព្រះបាទ ថៃ-សុង់ថា "មនុស្សនៅក្នុងប្រទេសចិន ត្រូវបង្ហាត់តែតាមប្រទេសចិន មិនដែលមានសៀវភៅ ១ ក្បាលឡើយ តែជាស្ទាត់ជំនាញខាងការបាញ់សត្វ, មានអំណត់, អត់ធន់នឹងរងា ជិះសេះបំផាយយ៉ាងអង់អាច, បាញ់កោទណ្ឌមិនដែលខុស" ។

នៅមានការដែលគួរសរសើរព្រះបាទថៃ-សុងមហារាជដោយឡែកទៀត គឺជាព្រះបាទអាលេក្សង់ទ្រ៍ មហាក្សត្រ ព្រះបាទណាប៉ូលេអុងក្តី សឹងផ្សាយព្រះរាជអំណាចចេញទៅបានដោយអាស្រ័យជីវិតមនុស្សក្ត-កយចង់ទៅជាច្រើនហ្មឺនសែនណាស់ តែព្រះបាទថៃ-សុងមហារាជទ្រង់ផ្សាយព្រះរាជអំណាចចេញបានដែនដីយ៉ាងសំបើមអស្ចារ្យ មិនចាញ់អា-លេក្សង់ទ្រ៍ ឬណាប៉ូលេអុងឡើយ តែទ្រង់មិនបំផ្លាញជីវិតរបស់មនុស្សច្រើនប៉ុន្មានទេ ទ្រង់ធ្វើការដោយអាស្រ័យកងទ័ពសេះក្លាហាន ឈាមត្រជាក់ ក៏អាចធ្វើឲ្យសត្រូវថយរត់ទៅបានមិនបាច់ប្រើកងទ័ពទាហាន អា-ស្រ័យការឈ្លាសប៉ុនប្រសប់ធ្វើឲ្យសត្រូវបែកសាមគ្គីឯងសី ស្ទើរតែទា-ហានចិនមិនបាច់ចេញច្បាំង ដល់វេលាចេញច្បាំងវិញក៏ទ្រង់ចេះប្រើវិធីបំផ្លាញជីវិតទាហានសត្រូវបានច្រើនបំផុត ប្រទេសចិនដែលរីកចំរើនឡើងក្នុងគ្រានោះ មិនមែនដោយអំណាចកងទ័ពទាហានទេ ប៉ុន្តែ

សម្រេចដោយគុណសម្បត្តិរបស់ព្រះបាទថៃ - សុរិន្ទមហាកដតែមួយព្រះអង្គប៉ុណ្ណោះ ។

ព្រះបាទថៃ-សុរិន្ទមហាកដទិវង្គតទៅ កាលពីឆ្នាំកុរសករាជ ១១៩៤ មានព្រះជន្មាយុ ៥៥ ព្រះវស្សា ព្រះបរមសពរបស់ទ្រង់គេកប់នៅក្នុងស្រុកបេន - ប៉ុន្តែវេលាដែលជិតទិវង្គតនោះ ទ្រង់មានព្រះបន្ទូលឲ្យគេសាងរូបក្សត្រិយ៍ផ្សេង ១ ដែលចំណុះព្រះអង្គ ព្រមទាំងរូបកដពាជីទាំង ៦ ដែលទ្រង់ធ្លាប់ប្រើក្នុងការសង្គ្រាមផង ។

## វគ្គទី ៥

## អធិរាជវង្សហាំង - សម័យរាជការផែនដី ធ្លាក់ទៅក្នុងកណ្ដាប់ដៃព្រះរាជិនី

ក្នុងប្រវត្តិពង្សាវតាររបស់ លាក់ខាន មានហេតុការណ៍ចំឡែកមួយដែលតែកើតមានឡើងជារឿយ ៗ គឺថាបើក្នុងរាជ្យផែនដីណា មានព្រះមហាក្សត្រទ្រង់ព្រះបរមតេជានុភាព ទំនុកបំរុងសម្បត្តិធ្វើស្រុកទេសឲ្យបានចំរើន ទាំងមានអំណាចយ៉ាងក្រៃលែងបំផុតហើយ ក្នុងរយៈវេលាជាបន្ទាប់តមក កាលមានព្រះមហាក្សត្រឡើងគ្រងរាជ្យថ្មីជាជំនាន់តមក សេចក្ដីចំរើនរុងរឿងនិងអំណាចរបស់ស្រុកទេស ក៏ប្រែទៅជាថយចុះទាំងសាបសូន្យទៅ ដោយកំហុសរបស់ព្រះមហាក្សត្រក៏មាន ដោយហេតុកេតុដទៃទៀតក៏មាន (មានត)

# អធិប្បាយសុភាសិតខ្មែរ

## ឃុនឧត្តមប្រឹជា ហ៊ប-ពិន រៀបរៀង

(តមកពីលេខមុន)

### ១០៣ ប្រើអង្គុំនៅចំរាក់ក្នុងភាគ

ពាក្យនេះអ្នកប្រាជ្ញប្រាប់ពន្យល់

មនុស្សដែលប្រើគេមិនត្រូវគល់ នាំឲ្យអស់ពេលវេលាកាត់ ។
ដើម្បីឲ្យជនបេះប្រើមនុស្ស ឲ្យត្រូវប៉ិនប្រសប់តាមពាក្យណាត់
អ្នកប្រាជ្ញលោកប្រាប់យ៉ាងម៉ឺងម៉ាត់ ឲ្យជនបេះចាត់មនុស្សតាំងឡាយ ។
បើប្រើមិនត្រូវតាមទំនួល នាំឲ្យមិនស្រួលមិនសប្បាយ
ដូចកាលកើតមានក្ដីអន្តរាយ ដល់នាយចៅហ្វាយអ្នកដាក់ប្រើ ។
មនុស្សញៀនទន់ដៃល្បែងកុំប្រើកាន់ ប្រាក់ឬប្រាក់រៀលឲ្យទៅធ្វើ
ការអ្វីមួយដោយអធ្វើ បើប្រើនឹងខូចខាតលិចលង់ ។
ហេតុនេះបោកណាលោកពោលណាត់ ឲ្យយើងប្រយ័ត្នកល់រូបអង្គ
ដើម្បីកេរ្តិ៍ទុកត្រឹមឲ្យគង់ កុំប្រើអង្គុំចំហ៊ុនកក់ ។

### ១០៤ ប្រើឆ្កែជាគាំព្រាប់, ប្រើលើយស្លាកា

សុភាសិតនេះលោកទូន្មាន

មិនឲ្យបៀនបៀនគោដ៏ឈ្លានពាន ឲ្យមានគារវៈប្រណិប័តន៍ត្រូវ ។
ចំពោះលើមនុស្សជាតិដូចគ្នា ឲ្យជាទីទុកដាក់ចិត្តទៅ
កុំឲ្យព្រះហើនការបោះបោរ ឲ្យនៅទន់ក្នុងជាដកប ។

បើនឹងនិយាយកែអ្នកណា ទោះជាជាតិខ្ពស់ឬជាតិទាប
ក៏គាយវាចាថែបសុភាព កបទាបអៀនមសណ្ដាប់ធ្នាប់ ។
ធ្វើថែបយ៉ាងនេះផុតពាក្យឡាយ រមែងស្រស់ស្រាយស្រស់ស្រាញ់ជាប់
ហេតុនេះលោកពោលទុកជាច្បាប់ ថា "ទុនដាក់គ្រាប់, ទឹយកស្លក" ។

### ១០៤ ផ្លែឈើជ្រុះមិនដែលឆ្ងាយពីគល់

សុភាសិតនេះហេតុប្រឌិត

តាមគោលធម្មជាតិដ៏មែនពិត បើយើងពិនិត្យគង់ឃើញត្រូវ ។
ក៏ពាក្យថាផ្លែឈើបានដល់ បុគ្គលជាសិស្សឬកូនចៅ
ឯពាក្យថាគល់គឺមេឪ ឬគ្រូប្រដៅសិល្បវិជ្ជា ។
ធម្មតាសិស្សគ្រប់ឬកូនចៅ ដែលនៅក្រោមមេនិងគ្រូបា
ឬក៏មាតានិងបិតា. រស់នាមិនឆ្ងាយចាកសណ្ឋាន
បើម្ដាយឪពុកឬគ្រូបា នោះមានចរិយាខូចសាហាវ
ក៏កូននិងសិស្សគង់តាមដាន លំអាននោះឯងមិនសូវប្លែក ។
បើម្ដាយឪពុកឬគ្រូបា នោះមានចរិយាល្អយ៉ាងឯក
ក៏កូនឬសិស្សមិនមានប្លែក បំផ្លែកពីលោកនោះប៉ុន្មាន ។
ប៉ុន្តែបើអ្នកដែលគ្រវែង គប់រហាន់ក្រើនក៏គង់បាន
ប្លែកចេញទៅទៀតក៏ពុំខាន បើគ្មានអប់រំមិនប្លែកគ្នា ។
លោកប្រៀបដូចផ្លែឈើវាងឆ្ងាយ មិនដែលជ្រុះឆ្ងាយពីគល់វា

តែងផ្ទះជិតៗមិនឃ្លាតឃ្លា   នេះជាធម្មតាស៊ីផលឈើ ។

## ១០៦ ពងមាន់កុំផ្ញើនឹងក្អែក

ពាក្យនេះជាពាក្យប្រាជ្ញប្រឌិត

ប្រដូចប្រៀបតាមហេតុពិត   ដែលយើងពិនិត្យក៏ឃើញថា ។
ពងមាន់ជាគ្រឿងឆ្ងាញ់បំផុត   បើផ្ញើនឹងក្អែកឲ្យរក្សា
មិនដែលគង់នៅដូចធម្មតា   ក្អែកវាកោក្កាឥតអំពើ ។
សេចក្ដីនេះដូចស្រីក្រមុំ   មានរូបសក្ដិសមកុំទុកផ្ញើ
នឹងប្រុសកំឡោះចិត្តសើរើ   បើផ្ញើនឹងខូចការពុំខាន ។
ឬមួយដូចមាសនឹងកាសប្រាក់   កុំផ្ញើនឹងអ្នកខ្សត់ធនធាន
ដល់ពេលក្រខ្សត់អត់ពុំបាន   យកវាយពុំខានមិនបានសង ។
ហេតុនេះបោកណាទូន្មានថា   កុំចិត្តសារ៉ាពេកកន្លង
យកពងមាន់ផ្ញើនឹងក្អែកផង   គួរវៀរចាកហោងកុំផ្ញើឡើយ ។

## ១០៧ ពងមាន់កុំជល់នឹងថ្ម

សុភាសិតនេះប្រាជ្ញបុរាណ

លោកពោលប្រដិតទុកទូន្មាន   កុំឲ្យឈ្លានពានហួសកម្លាំង ។
ហេតុនេះលោកពោលប្រៀបប្រដូច   នឹងអ្នកពាលចិត្តខូចដែលប្រណាំង ,
តសានឹងលោកអ្នកធំខ្លាំង   ឬក្រស្ដិតតាំងព្រះរាជា ។

បើធ្វើដូច្នោះសេចក្ដីទុក្ខ　　តែងដល់ទុក្ខមហិមា
នាំឲ្យលំបាកវេទនា　　អត្តកាយទ្រព្យជាប់ទោសពៃរ៍ ។
ដូចគល់ពងមាន់ដល់ទង្គិចថ្ម　　មិនមែននៅល្អដូចប្រក្រតី
តែងបែកចំណែកជាពីរបី　　សេចក្ដីនេះពិតឥតមុសា ។
ហេតុនេះពួកក្រស្ដីសក្ដិតូចទាប　　គួរធ្វើតាមភាពនៃគាត់គ្នា
កុំខាំងអ្នកធំឬក្សត្រា　　ពិតតែៗសព្វាហារគេទ្រព្យធន ។

១០៨ ពស់ប្រើង កន្ទ្រៃប្រើង

ពាក្យនេះដាស់តឿនជនទាំងឡាយ

ទាំងប្រុសទាំងស្រីគល់រូបកាយ　　ឲ្យខំខ្វល់ខ្វាយក្នុងកិច្ចខ្លួន ។
បើធ្វើការអ្វីត្រូវព្យាយាម　　រូតរះក្លាម ៗ យ៉ាងមាំមួន
ឲ្យបានរៀបរយដោយខ្ជាប់ខ្ជួន　　វៀងខ្លួនឲ្យការកើតរឹងប៉ឹង ។
កិច្ចការខ្លួនគេ ៗ ខំខែង　　កិច្ចការខ្លួនឯង ៗ ត្រូវប្រឹង
ដូចគល់ពស់ប្រឹងកន្ទ្រៃប្រឹង　　ឲ្យពេញទំហឹងកុំអាងគ្នា ។

១០៩ ឡើនៅជួកាំ, ឥតកាំនៅដៃ

សុភាសិតនេះហេតុអត្ថប្រាយ

អពីអំពើផងទាំងឡាយ　　ដែលគេខ្វល់ខ្វាយរកឃើញពិត ។
ដោយមានរបស់ជាកស្កាង　　សំអាងសំគាល់គោលពិនិត្យ
កាលមានអ្នកផងសួរដម្រិត　　គេពោលតាមពិតពុំជានិយ ។

ជា "ធ្មេញ បុរសពេញដាក់ស្ដូន ដោយគ្រួនខ្លួនឯងឥតសង្ស័យ"
ដូចតៀ ខាប់ក៏វក់ ខាងដៃ ទើបបានកែប្រែតាមចំនួន ។

### ១១០ កើតនេះពីសម្រាម

ពាក្យនេះលោកពោលដោយសង្ខេប

តមគោលធម៌ជាតិជាម្ចាស់ ហេតុ នៃគេមិនដែលធ្លើមជាដម្លោះ ។
ដើម្បីប្រមនុស្សប្រេះប្រែប្រួល កុំឲ្យមានគ្នាត់មានបាបគ្រោះ
ដៀតជាធម្មតាការស្រុះស្រួល តែងកើតពីព្រោះហេតុតូចតាច ។
ដូចមនុស្សចាស់ ១ ឬ អ្នកធំ ឃាតមេតួកក្រុមមានអំណាច
តំណត់គូរៀងពីអ្នកខាងក្រោយ តែងជាប់ពីអ្នកតូច ១ ទៅ ។
គឺដូចបារព្រោះពីចាស់គ្នា តែងស្ដុះស្ដាស់ពីឲ្យម្ដាយ
ចម្លងឈ្លោះតាស់តែងកើតទុក្ខក្ដៅ កាលជាលតទៅដល់កំពូល ។
ព្រោះការគេនាំដើរដំណើរឯងគ្នា ដែលជាបារព្រោះរបស់ខ្លួន
នោះបើរឿងតូចមិនក្រាស់ក្រួន គង់ផ្ទួនជាធំទៅក្តាម ១ ។
ទើបមានការសិតពោលដូចេះ ជា "ក្ដិចតែងនេះពីសម្រាម"
ជាពាក្យទូន្មានប្រាជ្ញចាស់លោកបាយ ឲ្យជនកាន់តាមដោយប្រយ័ត្ន ។

### ១១១ មនុស្សល្ងង់កុំប្រើឲ្យដំណើរការ

មនុស្សមានប្រាជ្ញាកុំប្រើឲ្យកាពុង

ពាក្យនេះលោកពោលតាមភាពមនុស្ស

ដើម្បីឲ្យប្រើកុំឲ្យខុស ... តាំងមនុស្សដែលប្រាជ្ញនឹងមនុស្សល្ងង់ ។
មនុស្សល្ងង់កុំប្រើឲ្យនិយាយ   កិច្ចការទាំងឡាយដើរខុសក្តង់
បើប្រើប្រែនខ្ចប្រែនភាគបង់   មិនបានគង់ទ្រង់ដូចប្រាថ្នា ។
ត្រូវប្រើអ្នកចេះឲ្យនិយាយ   កិច្ចការទាំងឡាយដើរថ្កុំថ្កើង
បើប្រើមនុស្សចេះមានប្រាជ្ញា   ទើបបានសុខាដូចបំណង ។
កុំបីប្រើមនុស្សអ្នកចេះដើត   ឲ្យប្រើនិងធ្វើការជួនខ្លួន
គឺប្រើកេតុនខុសទំនង   មិនត្រូវខ្លួនជាមិត្តឡើយ ។

១១២ ចាត់ចាងត្រូវ ជបជាងគ្នា

ពាក្យនេះលោកណាពោលហាមឃាត់

ឲ្យផងចេះទប់ចេះទល់មាត់   កុំចេះតែផ្ទាត់ពោលប្លែ ។
កុំកាន់តែខ្លួនមានវោហារ   ក្រេវក្រាងស្អាប់ឲ្យគាស្រូវ
កុំពោលចេះមួយខ្វាប់ចប់   កេរ្តិ៍គួរស្រូវកេស ។
ពាក្យណាមិនទាន់ពិតប្រាកដ   ចូរទំរិនឲ្យកុំទីសពាស
និយាយបរិហារតែពីសពាស   ក្រែងខ្លួនប្រាកដមានសម្បខ្ទិចចិត្ត ។
គួរទប់ទំនប់មាត់ឲ្យសុខ   ដូចជបមានគុណបុនឲ្យជិត
និយាយពាក្យណាគួរពិចារ្យ   ឲ្យពិតសមរម្យទើបបានសុខ ។

ហេតុនេះបុរាណពោលប្រកប ថា "ចាំតែមាត់ប្រែបដងមានទុក"
អ្នកណាចំណាំចាំយកទុក អ្នកនោះនឹងសុខសប្បាយក្រៃ ។

## ១១៣ មុជមិនជ្រៅទៅមិនឆ្ងាយ

ពាក្យនេះចាស់ៗពោលតាមពិត

តាមភាពនៃមនុស្សទាល់គំនិត ដែលគិតមិនលេចមិនល្អមជួន ។
គឺគិតការអ្វីដែលក្រៗ ឬការល្អៗយ៉ាងម៉ាំមួន
ដែលហួសវិស័យរបស់ខ្លួន គិតហើយមិនជួនមិនឃើញផាយ ។
រមែងត្អូញត្អែរព្រោះទាល់ចុប ថា "មុជមិនជ្រៅទៅមិនឆ្ងាយ"
ព្រោះហេតុនេះឯងលោកឧបរិយាយ ដូចបានអធិប្បាយមកខាងដើម ។

## ១១៤ យល់ញាតិឃ្លាតច្បាប់

បុរាណភាសិតនេះថ្លៃថ្លា

ជាពាក្យត្រង់ៗមិនប្រស្នា ដែលយើងរាល់គ្នាក៏ឃើញពិត ។
ធម្មតាពួកជនជាព្រៀងលាន ជាញាតិសន្តានតាំងឆ្ងាយជិត
កាលបើស្រឡាញ់គ្នាយ៉ាងស្និទ្ធ តែងគិតយោគយល់មុខមាត់គ្នា ។
បើកើតរឿងរ៉ាវអ្វីមួយ តែងជួយសង្គ្រោះឲ្យវៀនា
ទោះបីមានទោសធ្ងន់យ៉ាងណា ក៏តែងកុនគ្នាឲ្យបានស្រាល ។
បើទោសស្រាលស្រាប់តែសម្រួល ឲ្យញាតិបានស្រួលយ៉ាងវិសាល
ដើម្បីឲ្យញាតិបានត្រកាល ឈឺឆ្អាលឲ្យបានសុខសេរី ។

ទោះបីច្បាប់ថាត្រូវមានទោស ក៏គង់សន្ដោសប្រោសប្រណី
សម្រាលច្បាប់នោះឲ្យស្រាលទី ដោយក្ដីយល់មុខញាតិសន្ដាន ។
កាលបើដូច្នោះតែងឃ្លៀងឃ្លាត ចាកច្បាប់ព្រោះញាតិនាំខាន
ហេតុនេះអ្នកប្រាជ្ញពីបុរាណ ទូន្មានឲ្យយើងខំប្រយ័ត្ន ។

## ១១៥ រស់កុំគាប់ ងាប់កុំក្លួរ

ពាក្យនេះបុរាណពោលសរសើរ

ប្រៀបប្រដូចតាមដំណើរ នៃមនុស្សប្រសើរយ៉ាងឧត្ដម ។
ពោលគឺជាមនុស្សមានប្រាជ្ញ មានកាយវាចាចិត្តសមរម្យ
កាន់ធម៌កាន់សាសនាយ៉ាងគួរសម អ្នកតូចអ្នកធំគេគាប់អាន ។
ធ្វើបុណ្យឲ្យទានដល់ស្រមណ៍ព្រាហ្មណ៍ កាន់តាមឱវាទព្រះទ្រង់ញាណ
នោះពេលម៉ែត្រូវលំអាន រកស៊ីមានបានសុខចម្រើន ។
មានទ្រព្យសម្បត្តិចិត្តទូលាយ តែមិនខ្ជះខ្ជាយបះក្រវើន
រៀនធម៌រៀនអាថ៌ចេះដឹងច្រើន ចម្រើនការនា ហាត់ពត់ចិត្ត ។
នៅក្នុងបច្ចុប្បន្ននេះក៏ជា ទៅនាបរលោកក៏ល្អពិត
ដោយគេខំសាងខំប្រព្រឹត្ត កាយវាចាចិត្តយ៉ាងល្អក្រៃ ។
មនុស្សបែបយ៉ាងនេះប្រាជ្ញលោកគប់ ថា "រស់កំគាប់ងាប់ប្រពៃ"
ព្រោះក្នុងលោកនេះគេមានជ័យ មានជោគពេកក្រៃក្នុងលោកនាយ ។

១១៦ - លេងល្បែងអាប់យស

លេងពាល់តាំងដៃ

ពាក្យនេះវុត្តមប្រាសើរពេកណាស់

ជាពាក្យប្រដៅមនុស្សចាស់ៗ ឲ្យនឹកឃើញពាក្យស់ដោយស្មារតី ៗ
ជាមនុស្សចាស់ៗ ត្រូវនាំក្បួន ត្រូវតាំងសណ្ដាប់ធ្នាប់សេរី
មានកេរ្តិ៍ថ្លៃថ្នូរនិងប្រុងប្រយ័ត្ន ឲ្យគួរគេប្បីកែអ្នកផង ៗ
កុំធ្វើខ្ជះខ្ជាយដូចកូនក្មេង ដែលលេងនៅដីសេចក្ដីធ្ងន់
បើលេងសើចខ្លះត្រូវឃុំគ្រង ឲ្យសមទំនងមានសណ្ដាប់ ៗ
បើចាស់ឯណាល្ងង់មិនដឹង ប្រព្រឹត្តការល្បែងទាស់ចំណាប់
ជាមួយក្មេងៗ រមែងអាប់ យសសក្តិខ្ពស់ភ្លាប់ត្រូវឡប់ថោក ៗ
ដូចចាស់ៗខ្លះប្រើខ្សែលេង ទំពុកខ្ញុំក្មេងឥតប្រយោក
ប្អូនធាលៈក្មេងទ័ន្ធយកដៃវាយ ប្រមាថចំក្បាលគេឥតប្រណី ៗ
បើតុកជាចាស់ដែលគួរលេង នេះទីធំមិនក្មេងបើធណាក្តី
ក៏ចាស់មិនត្រូវសោភាលដេរស្តី ជាអ្វីឲ្យក្មេងខ្លួចយើងណា ៗ
ព្រោះហេតុតែក្មេងសេចក្ដីណាស់ យើងចាស់មិនត្រូវយកគោលសា
ហេតុនេះចាស់ៗ លោកតែងពោលថា លេងក្មេងកាលណាស៊ីឯងអាប់យស ៗ

១១៧ - ក្មេងក្មេងដូចគ្នាកុំវង្វេងបំផ្លៃ

## សុភាសិតនេះល្អខ្លួន

អ្នកប្រាជ្ញបុរាណលោកបានចងទុក　រៀបក្រងជាពាក្យប្រែប្រស្នា ។
ប្រាប់ពូជពង្សមនុស្សគ្រប់គ្នា　មិនដឹងគុណគេអាចរំលោភ
ឬគុណមាតានិងបិតា　ឬក៏លោកណាដែលគេជួយ ។
ជាអ្នកមានគុណច្រើនលើសលុប　តែមិនគោរពលោកម្តង
រំលឹកកាលពេលសោកសុខគួរ　បំពេរបំពួនគុណលោកនោះ ។
ទៅតាមវាសនាអ្នកឯទៀត　ត្រូវប្រយ័ត្នបៀតបៀនខាំគោះ
មាតាបិតាត្រូវឯងស្មោះ　ក្រែងគុណលោកនោះពុំបានដឹង ។
នេះប្រាជ្ញលោកពោលថាសេរី　"ដូចជាក្រពើវង្វេងបឹង"
ជាមនុស្សដែលគោលឥតមាំពឹង　តែងទទួលទុក្ខឥតសុខឡើយ ។

### ១១៨. ទំពាំងស៊ីអាកៀង តែងវៀងវិនាស

- ពាក្យនេះអ្នកប្រាជ្ញលោកប្រៀប

ប្រាប់ថាមកក្រោកនៃផ្លូវចិត្ត　ដែលបានប្រព្រឹត្តផ្ទុយខុសណា ៖
មើលតែពាក្យនឹងជាប់ទប់　បញ្ជប់ឲ្យកន្លងទៅ
ឲ្យឆាប់ឲ្យលេចបង្កើតក្តី　កម្មអ្នកណាអ្នកនោះបាន ។
បើអ្នកមានទ្រព្យច្រើនដក់　ទោះកក់យ៉ាងណាតស៊ូតក្លាស
ចេះកេងទ្រព្យជនឬប្រាក់ការ　មិនសូវវិនាសខូចប៉ុន្មាន ។
តែអ្នកក្រខ្សត់អត់ទ្រព្យដក់　បើគេមិនវិនាសប្រាណ

អស់ព្រាត់អស់កាសអស់ធនធាន កើតចិត្តញ្ញាណពាលហ៊ានលួចប្លន់ ។
តែផលផ្ទាត់នេះច្រើនអន្តរាយ ផលរូបកាយត្រូវទោសទណ្ឌ
កើតទុក្ខវេទនាឃើញទាន់ហន់ ទោះខាងបច្ចុប្បន្នក្រោយផងហោង ។

### ១១៩ សត្វប្រចៀវ ចាំមែកពោធិ៍ ស៊ីផ្លែជ្រៃ

ពាក្យនេះលោកពោលជាប្រស្នា

អំពីដំណើរតំណពកិរិយា នៃមនុស្សសាវ៉ាចិត្តញាប់ញ័រ ។
ថ្ងៃមុនជាមនុស្សមានវិរិយា បានរៀនវិជ្ជាលោកប្ដូរធម៌
នឹងគ្រូណាមួយដោយស្មោះសរ ថ្ងៃក្រោយគេចបះបោលគ្រូមុន ។
ទៅគប់នឹងអ្នកឯណាទៀត ត្រឡប់ប្រែតបៀតរំលុបគុណ
ពោលពាក្យទទោះយ៉ាងទារុណ ត្មះតៀលគ្រូមុនឲ្យឆោឡោ ។
យ៉ាងនេះជាប្រដៅប្រាជ្ញបញ្ញត្តិ ឲ្យឈ្មោះហៅ "សត្វប្រចៀវ"
ឡើងចាំលើមែកនៃដើមពោធិ៍ "តែពោលទៅស៊ីផ្លែជ្រៃ" ។
ពុំនោះដូចអ្នកមានវិរិយា បានរៀនវិជ្ជាល្អប្រពៃ
ប៉ុន្តែមិនបេះគន់គិតគៃ តាមន័យដែលខ្លួនធ្លាប់រៀនមក ។
កាលធ្វើការអ្វីធ្វើអៀនប្រៀន មិនតាមរបៀនដែលរៀនយក
ត្រឡប់សារ៉ាជាប្រែលប្រែក ទៅយកកិច្ចការបែបបពោ ។
យ៉ាងនេះក៏ប្រាជ្ញលោកបញ្ញត្តិ ឲ្យឈ្មោះហៅ "សត្វប្រចៀវ
បានឡើងមកចាំលើមែកពោធិ៍ តែលោទៅស៊ីផ្លែជ្រៃ" ដែរ ។

## ១២០ ស្រូវឲ្យសាច់ កុំបង្ហាញព្រៃ

ពាក្យនេះលោកពោលប្រដៅអ្នក

ដែលចេះចំពោះឲ្យចេះលាក់ ចេះប្រាប់ដល់អ្នកដទៃទៀត ។
ប៉ុន្តែឲ្យប្រាប់តែស្រាល ៗ យ៉ាងល្អគ្រាកាលត្រូវក្បិតក្បៀត
កុំប្រាប់ឲ្យអស់ពោលចង់មៀត ត្រូវទៀតបង្ការទុកខ្លួនឯង ។
ដូចអ្នករកស៊ីទទួលទាន ដែលបានដឹកការអ៊ីវ៉ែន
កុំប្រាប់ឲ្យគេស្គាល់កំណែន កន្ទែងយ៉ាងធ្វើដើមកំណើត ។
ប្រាប់តែរបស់ដែលបានស្រាប់ កុំប្រាប់ដល់ទីល្អយ៉ាងកើត
បើប្រាប់គេទៅគេនឹងកើត ស្ទុះស្ទើតទៅរកបានឆាប់ ៗ ។
ឬមួយអ្នកចេះចំណេះអ្វី បានដឹងសេចក្តីល្អចំណាប់
ពីទីណាមកត្រូវតែក្តាប់ បើប្រាប់ដល់គេកុំប្រាប់ដើម ។
ប្រាប់តែចុង ៗ ឲ្យគេដឹង ទុកគ្រាន់ទីពឹងល្អយ៉ាងឆ្នើម
របស់ខ្លួនឯងយកសម្រើម ព្រោះខ្លួនដឹងដើមល្អប្រពៃ ។
ហេតុនេះអ្នកប្រាជ្ញលោកហាមផ្តាច់ ថា "ស្រូវឲ្យសាច់" កុំប្រាប់ព្រៃ
ដើម្បីឲ្យជនផងចេះលៃ គិតតែយកគ្រាន់ជាក់ខ្លួនឯង ។

## ១២១ ស្រូវស្វាប់នៅគាប់ រសធម៌កុំបីបង់

ពាក្យនេះលោកពោលបន្ទំចិត្ត

ឲ្យជនខំប្រឹងប្រព្រឹត្ត ខំរិះខំគិតខាងផ្លូវធម៌ ។

ឲ្យមានចិត្តដុតចិត្តត្រេកអរ　ចំពោះធម៌អាចិត្តផ្សះស្មោះសរ
គឺច្បាប់វិន័យដ៏បវរ　ដែលជាគោចរបស់ចិត្ត ។
ដូចសីលសមាធិបញ្ញា　ដ៏ជាសាសនាព្រះវិជិត
បើបានជាកាន់ត្រូវកាន់ពិត　ទៀងត្រង់ដោយចិត្តកាយវាចា ។
ព្រោះបើមានអ្នកណាបង្ខំ　ថាកុំប្រព្រឹត្តដូច្នោះណា
សូម្បីលះជីវិតនៃអាត្មា　មិនលះសាសនាមិនជំនឿណាយ ។
មនុស្សបែបយ៉ាងនេះលោកពោលថា　ជាមនុស្សថ្លៃថ្លាសុខសប្បាយ
ទាំងក្នុងលោកនេះនឹងលោកខាងនាយ　ព្រោះគេខ្វល់ខ្វាយក្នុងផ្លូវចិត្ត ។
ហេតុនេះលោកពោលជាគ្រូ　ថាត្រូវតែស៊ូលះជីវិត
កុំបីលះធម៌ដ៏មែនពិត　ត្រូវធ្វើជូនចិត្តឲ្យបានល្អ ។

១៤៤ សំដីជាឋកា, លេខ ១៥.គោ,

ររតត្រូវជាត្រី

ពាក្យនេះលោកពោលតាមការពិត

បើយើងត្រេកអរនឹងពាក្យ　ក៏ឃើញថាពិតប្រាកដណាស់ ។
អ្នកចេះពាក្យនិងលេះហើយ　តែពាក្យទៅឈ្លើយពោលមិនច្បាស់
និយាយដ៏ការពិតនេះ　ស្តាប់ពាក្យមិនលះត្រង់សេចក្តី ។

ចំណែកអក្សរបេះតែឈ្មោះ    បេះព្រមទាំងលេខទាំងសំដី
កុំពេលមានកិច្ចរឿងអ្វី    គេយកសំដីជួយដោះខ្លួន ។
អ្នកបេះអក្សរលេខនព្វន្ធ    បេះគិតដេះគន់ត្រូវតាមក្បួន
តែបើសំដីមិនចាំមួន    ច្រើនតែត្រៀមខ្លួនចាំកក់ក្រា ។
ឲ្យអ្នកផ្ដល់ប្រាជ្ញាទាំងនិយាយ    ឬគេអធិប្បាយសេចក្ដីណា
ហេតុនេះបុរាណលោកពោលថា    ដូចមាត់កាទាំងដើមហោង ។

១២៣ - ហៅហានពេក ដេកមិនស្រួលតាំ

ពាក្យថា "ហៅហាន" ប្រែថា "ចោរ"

បានទាំងមនុស្សប៉ិនក្ដីណាប    ឥតខ្មាសការខ្លាចមនុស្សផងគ្នា ។
ដេញចាកលួចដាក់ថ្ងៃអ្នកស្រុក    ឲ្យគេកើតទុក្ខកើតវេទនា
ឲ្យខូចឲ្យខាតបង់ទ្រព្យា    ហើយពុតពាលាអាក្រក់ក្រៃ ។
មនុស្សកាចហៅហានឈ្លានពេក    ច្រើនដេកមិនលក់ពេញយប់ថ្ងៃ
មិនសូវនៅស្រុកច្រើននៅព្រៃ    ដោយភ័យខ្លាចខ្លាំងគេចាប់បាន ។
ដូចពួកប្រមឹកពីកស្រុក    ស្រវឹងឡប់ឡាកាចសាហាវ
ដើររពាលរករឿងពាក្យញាតិសន្ដាន    ចាំគេវាយមិនសូវឈប់ ។
មនុស្សបែបនេះឯណាកាលបើភ្ញាក់    ដល់មាត់ផ្អើលមិនបានទប់
ដោយគិតថាក្រែងគេប្រាប់    គេឡប់កេរឿងដល់ខ្លួនវិញ ។

តែងដេកមិនលក់ព្រោះផលកាប    ដែលខ្លួនកំណាចកើតទុក្ខម្នេញ
ហេតុនេះទើបលោកពោលរំគេញ    ដូចខាងដើមមិញឲ្យបានដឹង ។

១២៤ លើះលោះឡូឡា
លោកជាអាប់យស
ពាក្យនេះលោកប្រាប់បែបបទ

ឲ្យជនធ្វើកេរងរម្យទម    សក្តិសមជាមនុស្សសណ្តាប់ធ្នាប់ ។
កុំឲ្យលេះលោះពោលឡូឡា    ដែលជាវាចាមិនគួរគាប់
អ្នកមានយសសក្តិច្រើនទុនកាប់    ដោយពាសចំណាប់ពោលវាចា ។
ខាងពួកស្រី ៗ លោកប្រដៅ    ឲ្យនៅក្នុងច្បាប់សំរាប
សង្រួមថ្នមយសនៃអាត្មា    ដែលជាភាពស្រីឲ្យរម្យទម ។
បើស្រីលេះលោះឬឡូឡា    នឹងខូចកិរិយាដ៏ឧត្តម
ដែលពួកអ្នកស្រុកគេនិយម    មិនសមជាស្រីគ្រប់លក្ខណ៍ឡើយ ។

១២៥ អណ្តាតជាអាទិការក្នុង, ស្លាប់ជង
របស់ជង គឺព្រោះអណ្តាត
ពាក្យនេះបាតណលោកអភិប្រាយ

អំពីសុភាពនៃរូបកាយ    ពួកមនុស្សតាំងឡាយតាមទំនង ។
រូបកាយមនុស្សយើងមានអណ្តាត    លោកទុកជាអាទិ៍ជាដើមទង
ជាគ្រឿងប្រើមួយល្អក្នុង    ខូចផងជាធងតាំងពីខាង ។

អណ្តាតជាគ្រឿងសម្រាប់ផ្ចាត់ ហាហត់និយាយបានគ្រប់យ៉ាង
បើផ្ចាត់ទៅស្រួលក៏ជាផាង រុះរើក៏ល្អះល្អាយស្រួលចំណាប់ ។
បើផ្ចាត់មិនស្រួលក៏ទីសពាស ពីសពាសញាក់ល្មើកពិបាកស្តាប់
ជួនកាលផ្ចាត់ទៅបង់អត្ថ មិនដាច់ប្រសើរនាំអន្តរាយ ។

ជួនកាលផ្ចាត់ទៅត្រូវចំនួល ស្រួលបួលបានសុខបានសប្បាយ
នាំឲ្យចម្រើនដល់រូបកាយ នៃអ្នកបរិយាយពាក្យណាសំណា ។
ទោះបីត្រូវទោសដល់ទៅស្លាប់ អណ្តាតសារស័ព្ទពោលដោះសា
ឲ្យរួចទុក្ខទោសនៃគាត្រា ដោយមានប្រាជ្ញាបេះនិយាយ ។

ជួនកាលសុខ ៗ ក៏ទៅផ្ចាត់ ឲ្យភ្លាត់ចំណាប់ខ្លួនអន្តរាយ
កើតជាទុក្ខទោសដល់រូបកាយ ព្រោះតែនិយាយខុសទំនង ។
ហេតុនេះបោរាណថា "អណ្តាត ជាមុខជាបាតពេកមន្ទង
នាំខ្លួនឲ្យស្លាប់ឲ្យរស់ផង" ដូចប្រាជ្ញបានបង់មតខាងដើម ។

## ១២៦– អ្វស សម្រាស់ ប្រទះពាក្យ

ពាក្យនេះជាពាក្យពោលពើបពះ

ក្នុងពេលដែលពោលជួបប្រទះ ទឹងពាក្យអ្នកខ្លះនិយាយស្តី ។
ដូចពេលណាមួយមានអ្នកណា គេពោលចរចាថាអ្វី ៗ
ឬដេរប្រទេចកូនប្រុសស្រី អ្នកមួយក៏ស្តីត្បេរ ៗ គ្នា ។

អ្នកមុនបានឮពាក្យអ្នកក្រោយ    ក៏ឲ្យសំដីតបតថា
ដោយស្មានថាគេជេរគ្នា    រើសយកពាក្យគេដាក់ខ្លួន ។
កើតទៅជាឈ្លោះទាស់ទែងគ្នា    តតាំងទៅមកយ៉ាងម៉ាំមួន
ដោយជួបប្រទះប៉ះពាក្យខ្លួន    ដែលខ្លួនអ្នកស្ដាប់មិនឲ្យច្បាស់ ។
ហេតុនេះបោកណាលោកពោលប្រាប់    ថាស្ដាប់ពាក្យគេលំបាកណាស់
បើបានជាស្ដាប់ៗឲ្យច្បាស់    «ក្រែងស្រូសស្រមាស់ប្រទះពាក្យ» ។

អវសាន

---

## ពុទ្ធបុព្វជាតក

# ឃុនសោភាភក្តី អ៊ិម-ភិន

### ផ្ដើមរឿង

ធម្មតាមនុស្សទាំងអស់ក្នុងលោកនេះ រមែងមានការប្រស្រ័យទាក់ទងគ្នាដោយសេចក្តីសង្គ្រោះទៅវិញទៅមក ដូចយ៉ាងមាតាបិតា នឹងបុត្តធីតា គ្រូបាអាចារ្យនិងសិស្សានុសិស្ស ស្វាមីនិងភរិយាជាដើម ៗ អ្នកដែលបានធ្វើសេចក្តីសង្គ្រោះគេមុនដំបូងឈ្មោះថាបុព្វការី អ្នកដែលបានទទួលសេចក្តីសង្គ្រោះអំពីសំណាក់បុព្វការីបុគ្គលនោះ ហើយសំដែងសេចក្តីតបគុណវិញ ឈ្មោះថាកតញ្ញូកតវេទី; បុគ្គលទាំងពីរពួកនេះបើបានប្រព្រឹត្តស្មោះត្រង់នឹងគ្នាទៅវិញទៅមក រមែងបានសេចក្តីសុខ-ចំរើនក្នុងលោកនេះនិងលោកខាងមុខ ។ ឯបុគ្គលទីពីរដែលហៅថាកតញ្ញូកតវេទីនោះ ឃើញថាកម្រមានណាស់ក្នុងលោកនេះ សម្បូរតែខាងបុគ្គលដែលមើលគុណឬបំភ្លេចគុណ គេហៅថាអកតញ្ញូ ។ តាមច្បាប់ទំ-យមទុកមកថា: អ្នកដែលលុបគុណមើលគុណ មិនឃើញគុណគេ នឹងទៅជាមនុស្សអាក្រក់បំផុតក្នុងបណ្ដាមនុស្សទាំងអស់ ហើយនឹងត្រូវទទួលនូវទុក្ខទោសនិងភ័យអន្តរាយដោយអនេកប្រការ ក្នុងអត្តលោកនិងបរលោកជាប្រាកដ ។ សូមស្រង់យកចម្លងជាតកមកប្រកបសូត្រក្នុងទីនេះ

ដើម្បីឲ្យឃើញជាពស្តុតាង ហើយគ្រាន់ជាគ្រឿងប្រដាប់សតិបញ្ញានៃអស់លោកអ្នកដូចសេចក្តីតទៅនេះ :

អតីតេ ពារាណសីរញ្ញោ សត្ត បុត្តា អហេសុំ ។ តេសំ សព្វជេដ្ឋកោ បទុមោ ណាម កុមារោ ពោធិសត្តោ ។

បពិត្រអើយ ក្នុងកាលដ៏ចំណាំទាំងកំបាំងបាត់ស្ងាត់កន្លង រំលងយូរណាស់ទៅហើយ ឰដ៏កាលនោះ ព្រះចៅក្រុងពារាណសី មានព្រះរាជបុត្រា ៧ អង្គ ។ បណ្តាព្រះរាជឱរសទាំង ៧ អង្គនោះ បទុមរាជកុមារពោធិសត្វជាបងច្បងលើរាជកុមារទាំងអស់ ។ កាលនោះ ព្រះចៅក្រុងពារាណសីជាព្រះវររាជបិតា ទ្រង់ព្រះចិន្តាថា : ព្រះរាជកុមារទាំងនេះតទៅ មុខជានឹងនាំគ្នាសម្លាប់អញ ហើយដណ្តើមយករាជសម្បត្តិតែសព្វៗ ខ្លួនពុំខានឡើយ; លុះទ្រង់ព្រះចិន្តាឃើញយល់ដូច្នេះហើយ ក៏កើតសេចក្តីរង្កៀសសង្ស័យចំពោះព្រះរាជបុត្រាទាំងនោះ ទើបមានព្រះបន្ទូលថា : ហៃបុត្រស្ងួនសំឡាញ់មាសឪពុកទាំងឡាយអើយ ! បាកុំនៅក្នុងទីនេះឡើយ ចូរបានាំគ្នាចេញទៅនៅក្នុងទីដទៃសិនទៅ ។ ទម្រាំតែដល់គ្រាដែលអំណើះតអំពីបិតាទៅ សឹមបានាំគ្នាមកទទួលយករាជសម្បត្តិជាខាងក្រោយចុះ ។ ឯព្រះរាជកុមារទាំងនោះ ព្រមទាំងភរិយារបស់ខ្លួន ក៏នាំគ្នាថ្វាយបង្គំលាព្រះវរមាតា-បិតាហើយចេញទៅអំពីនគរ ។ លុះដើរៗ ទៅបានទៅដល់ផ្លូវដាច់ស្រយាលក៏ដាច់បាយដាច់ទឹកនៅក្នុង

កណ្ដាលអត្វាធ៌ គេស្បៀងអាហារបរិភោគពុំបាន ក៏ចូលគ្នាកាប់សម្លាប់ភរិយានៃព្រះរាជកុមារទៅជាមុន ចែកសាច់ជា ៧ ចំណែក ហើយបរិភោគសាច់ដែលជាចំណែករបស់ខ្លួនតែរៀង ១ ខ្លួន ។

ឯនៅថ្ងៃនោះ ព្រះបរមពោធិសត្វអគ្គមហាបុរសរ័ត្ន ព្រះអង្គត្រូវបានតែ ២ ចំណែក គឺព្រះអង្គ ១ ចំណែក ភរិយារបស់ព្រះអង្គ ១ ចំណែក ។ គឺបណ្ដាចំណែកពីរដែលខ្លួនទទួលបានមក នោះព្រះអង្គដកលាក់ទុក ១ ចំណែក ៗ រៀងរាល់ថ្ងៃមិនបរិភោគឡើយ បរិភោគតែ ១ ចំណែកជាមួយនឹងភរិយា ។ ឯព្រះរាជកុមារទាំងនោះ ក៏សម្លាប់ស្ត្រីទាំង ៦ នាក់ ក្នុង ១ ថ្ងៃមួយ ៗ យកសាច់មកចែកគ្នាបរិភោគតាមន័យនេះរៀងរាល់ថ្ងៃ រហូតមកដល់ថ្ងៃជាគំរប់ ៦ ។ ចំណែកព្រះបរមពោធិសត្វអគ្គមហាបុរសរ័ត្ន វិហតុតែព្រះអង្គមានប្រាជ្ញាឈ្លាសវៃ បានរំលែកទុកចំណែកដែលត្រូវបានខ្លួនមួយចំណែក ៗ តែរាល់ ៗ ថ្ងៃ ទើបដល់មកថ្ងៃទី ៧ ដែលត្រូវនឹងសម្លាប់ភរិយារបស់ខ្លួន នោះព្រះអង្គនៅសល់ចំណែកទាំង ៦ ដែលបានរំលែកលាក់ទុកពីថ្ងៃមុន ៗ មក ។ ព្រះអង្គក៏ប្រទានឲ្យចំណែកទាំង ៦ ដល់ព្រះរាជកុមារទាំងឡាយ ដែលមានប្រាថ្នាដើម្បីនឹងសម្លាប់ភរិយារបស់ព្រះអង្គ ហើយទ្រង់ពោលថា ៖ ម្នាលអ្នកទាំងឡាយ ក្នុងថ្ងៃនេះ អ្នកទាំងឡាយ ចូរបរិភោគចំណែកទាំងនេះសិនចុះ ចាំដល់ថ្ងៃស្អែកសឹមយើងនឹងចែកលែកគ្នាទៅទៀត ។ លុះដល់វេលារាត្រី កាលព្រះរាជកុមារ

ពីនោះនារីកំពុងដេកលក់ស្កប់ ព្រះអគ្គិក៏នាំភរិយារបស់ព្រះអគ្គិរត់គេចទៅ អំពីទីនោះ ។ លុះដើរឆ្ងាយបន្តិចទៅភរិយាអស់កំឡាំងមិនអាចដើរទៅ ទៀតបាន ទើបព្រះអគ្គិលើកភរិយាបញ្ចុះលើស្មា ហើយរត់ប្រឹងដើរទៅ កាលព្រះអាទិត្យរះឡើងពេលព្រឹក ក៏បានជួបផ្លូវឆ្ងាយដាច់ស្រយាល នោះផុត ។ ឯភរិយាបានពោលថា បតីគ្រូជាស្វាមី ខ្ញុំស្រេកទឹក ខ្លាំងណាស់ ។ ព្រះបរមពោធិសត្វ កាលណាបើរកទឹកពុំបានឱ្យភរិយា ផឹក ក៏វះភ្លៅដោយព្រះខាន់ជ័យមុត យកឈាមឱ្យភរិយាផឹក ។ ផងចាំងពីរោក ស្វាមី ភរិយានោះ ដើរដល់ដាច់ទៅ បានដល់មហា- គង្គា ១ ក៏ធ្វើបណ្ណសាលា ១ នៅក្បែរទន្លេគង្គានោះ ហើយក៏នៅ គង្វាលនោះទៅ ។ កាលនោះមានពួកមនុស្សជាច្រើន ចាប់បានចោរ ម្នាក់ដែលមានទោសកាត់ហុសព ព្រះព្រាហ្មហើយនាំយកទៅកាត់ដៃជើង -ត្រចៀក និងច្រមុះឱ្យកំបុតអស់ ហើយដាក់ទៅទូកតាំងបណ្ដែត ទៅតាមទៅក្នុងទន្លេគង្គានោះទៅ ។ ឯបុរសកំបុតក៏ស្រែកថ្ងូរដោយសារ ជំងឺខ្លាំង ហើយក៏អណ្ដែតទៅដល់ទីនោះ ។ ព្រះបរមពោធិសត្វបានឮបុ- រុទនោះហើយ ក៏ទៅព្រឹងលើកបុរសកំបុតនោះ ដោយសេចក្ដីករុណា អាណិតអាសូរ នាំយកទៅកាន់បណ្ណសាលា ប៉ុន្មានថ្ងៃ ប្រពន្ធភរិយា បំរុងដំបៅ ហើយក៏ចូលទាំងឡាយបមាទ្រលានខនប្រៀ ដោយសំពត់ជាដើម ។ ឯភរិយាព្រះបរមពោធិសត្វមហាបុរសនោះ ក៏ត្រូវរំលឹមបុរសកំបុតនោះ

គំនិតគេ ប៉ុន្តែកាកស្អុះរាល់ថ្ងៃ ។ កាលនោះព្រះបរមពោធិសត្វ
តែងខ្ញុំ-ប្រុសកំបុកនោះឲ្យនៅក្បែរស្រែមបេះជាមួយនឹងភរិយា ហើយ
ទ្រង់ចេញទៅស្រុកវេទលាល ដោយព្រះអង្គឯង នាំយកមកពិចារណា
ទ្រង់ថែរក្សាប្រុសកំបុក រៀងរាល់ថ្ងៃ ពាល់គបានសះជាប្រុសនោះដោយ
ស្រួលបួល ។ ឯនារីនោះជាស្រីអប្រិយ មានគំនិតអាក្រក់ ក្រៅចិត្តស្វាមី
កាលបានឃើញសង្ហាត់ហើយ ក៏បណ្ដោយចិត្តប្រព្រឹត្តខុសនឹងអាកំបុកផត
មានចិត្តគាត់ត្រូវផ្លាស់ស្វាមីវេទ្ទិបង្ខាមខ្ញុំ ហើយ ក៏បានប្រព្រឹត្តមិច្ឆា-
ចារៈជាមួយនឹងអាកំបុកនោះទៅ, មិនតែប៉ុណ្ណោះសោត គិតគោកលះបាយ
ខ្ពីនឹងសម្លាប់ព្រះពោធិសត្វជាស្វាមីរបស់ខ្លួន ពាល ហើយក៏ធ្វើជាក្លែងទិ-
យាយថា: បពិត្រអ្នកជាស្វាមី កាលដែលខ្ញុំជិះលើស្ពាន់ទេញផុតអំពី
ផុតឆាយភាចស្រែយោពរខាងកើត បានឃើញភ្នំ ១ ជាំ ហើយខ្ញុំក៏បានតាំងទី
សច្ចា បណ្ដាំចំពោះអុកស្មីនទស្សនា: បពិត្រលោកទេវតាគ្រប់ភ្នំម្ចាស់
ដ៏ស័ក្តិ! បើសិនណាជាខ្ញុំព្រមទាំងស្វាមីរបស់ខ្ញុំបានរួចជីវិត នឹងយកផ្កាភ្លឺផង
ម្ហូប ហើយបានរសដែលជាគ្រឿងសក្ការៈ ខ្ញុំនឹងត្រឡប់មក ធ្វើពលិកម្មជាថ្វាយ
លោកក្នុងកាលនោះពុំខាន; ឥឡូវនេះដល់ពេលដែលខ្ញុំនឹងត្រូវធ្វើពលិកម្ម
ថ្វាយដល់ទេវតានោះ ។ នាងនិយាយប៉ុណ្ណោះហើយ ក៏នាំព្រះពោធិសត្វ
ទៅឯភ្នំនោះ លុះដល់ហើយ ទើបនិយាយនឹងព្រះពោធិសត្វជាស្វាមីថា:
បពិត្រអ្នកជាស្វាមី, ខ្ញុំសូមអង្វរថាទេវតាធំនេះ ខ្ញុំនឹងធ្វើប្រទក្សិណអ្នក

៣.ផ្ទុំ ហើយថ្វាយបង្គំអង្គជាមុនសិន រួចហើយសឹមធ្វើពលិកម្មបូជាផល-
ទៅតាមក្នុងកាលជាខាងក្រោយ ។ ស្រេចក្រោយពោលពាក្យយ៉ាងនេះ
ហើយ ក៏ឲ្យព្រះពោធិសត្វឈរបែរមុខឈមទៅកាន់ជ្រោះភ្នំ ហើយ
ធ្វើអាការៈហាក់ដូចជាស្ត្រីមានគ្រាញ់ ដើម្បីថ្វាយបង្គំបូជាដោយភក្តីទាំង-
ឡាយ ឈរនៅពីខាងក្រោយខ្នងហើយច្រានព្រះពោធិសត្វទំលាក់ទៅ
ក្នុងជ្រោះភ្នំនោះទៅ ។ រួចហើយក៏ម្នាត្រឡប់វិលទៅកាន់សំណាក់
បុរសកំពុតនោះវិញដោយប្រញាប់ប្រញាល់ ។ ឯព្រះបរមពោធិសត្វ
មហាបុរសរ័ត្ន កាលដែលធ្លាក់ចុះទៅក្នុងជ្រោះនោះ ហេតុតែបុណ្យ
សម្ភារព្រះបារមីដែលព្រះអង្គបានសាងទុកមកពីបុព្វជាតិ ក៏ធ្លាក់ទៅទើរ
លើគុម្ពឈើស៊ីមព្រៃ ១ លើចុងទទុម្ពរ ( ដើមល្វា ) ១ ដើម ដែលជាឈើ
ដុះចន្លោះតែថ្មដ៏មិនអាចដើរចុះទៅក្នុងទីដទៃបានឡើយ ។ ក៏បេះផ្លែទទុម្ពរ
អង្គុយបរិភោគនៅលើមែកឈើនោះឯង ។ ជួនជាពេលនោះ
មានស្ដេចទន្សោង ១ មានសរីរកាយៈដ៏ធំ ជាសត្វធ្លាប់ឡើងអំពីជើងភ្នំទៅ
រកស៊ីផ្លែល្វានោះ ។ សត្វទន្សោងនោះ កាលឡើងមកស៊ីផ្លែឈើនោះ
ស្រាប់តែក្រឡេកមើលទៅឃើញព្រះបរមពោធិសត្វ ក៏មានសេចក្ដី
វិស្វាសៈស្និទ្ធស្នាលនឹងព្រះអង្គ ទើបសួរពីហេតុដែលព្រះពោធិសត្វមក
ក្នុងទីនោះ, កាលបានស្ដាប់ដំណើររឿងសេចក្ដីនោះសព្វគ្រប់ហើយ ក៏ឲ្យព្រះ
បរមពោធិសត្វអគ្គមហាបុរសរ័ត្នអង្គុយនៅលើខ្នងរបស់ខ្លួនហើយក៏ឡើង

អំពីព្រោះក្តីអោយញោះទៅជាក់នៅនាមហាមគា ហើយក៏ត្រឡប់វិលចូល ទៅកាន់ព្រៃបាត់ទៅវិញទៅ ។ ឯព្រះបរមពោធិសត្វទ្រង់ទៅកាន់បច្ចន្ត-គ្រាមហើយនៅក្នុងស្រុកនោះ; លុះអំណើះតអំពីព្រះវររាជបិតាទៅ ក៏បានទទួលសោយរាជ្យជាស្តេចទ្រង់ព្រះនាមថាព្រះបាទបទុមរាជ គ្រប់គ្រងរាជសម្បត្តិជាដំណតវង្សមក ព្រះអង្គបានសាងសាលាសម្រាប់ឲ្យទាន ៦ ខ្នង ហើយចំណាយទ្រព្យកូន ១ ថ្ងៃ ៦ សែនកហាបណៈឲ្យទាន តែរាល់ៗថ្ងៃឥតមានលោះថ្ងៃណាមួយឡើយ ។

កាលនោះស្ត្រីបាបអប្រិយការឡកណ្ណីជូជាតិឥតល័ក្ខណ៍នោះ បានបញ្ចុះអាក់ពុតលើស្មាដើរចេញមកអំពីព្រៃ ត្រាច់ដើរទៅស្វែងរកសូមទានបាយចំណីគេសព្វច្រកល្ហកឥតមានសល់ចន្លោះ ក្នុងផ្លូវជាលំនៅនៃមនុស្សម្នាមហាជនជន យកមកចិញ្ចឹមរក្សាបុរសពិការនោះជាធម្មតា កាលណាមានគេសួរថា: បុរសនេះត្រូវជាអ្វីនឹងនាង វាក៏តាំងពោលថ្លែងរៀបរាប់ប្រាប់ថា, យើងទាំងពីរនាក់ជាបងប្អូនជីដូនមួយនឹងគ្នា តែខ្លួនខ្ញុំជាធីតារបស់ឪពុកធំខាងម្តាយនៃបុរសនេះ, ឯបុរសនេះ ជាកូនរបស់ម្តាយមីងខ្ញុំ ពួកចាស់ទុំបានផ្សំផ្គុំខ្ញុំឲ្យជាភរិយានៃបុរសពិការនេះ ។ ខ្លួនខ្ញុំឯងក៏ស្ម័គ្រតែទំរើនថែរក្សាស្វាមីរបស់ខ្លួន សូម្បីមានទោសធ្ងន់ដល់ថ្នាក់ដែលគេត្រូវសម្លាប់ចោលយ៉ាងនេះក៏ដោយ ចេះតែទំរាច់ស្វះស្វែងរកសូមទានបាយចំណីគេយកមកចិញ្ចឹមរក្សាគ្នាទៅ ។ ពួកមនុស្សបានឮបិដ

ស៊ាំសព្វព្រៀបពក់ក្បាកប្រាប់ផ្ទួ ប្តោះហើយក៏គិតថា ៖ នាងនេះជាមាន សេចក្ដីគោរពប្ដិបត្តិប្ដីណាស់តើ ក៏នាំគ្នាឲ្យក្រោយបរជាច្រើន បានឲ្យ តាំងកន្ត្រែងផ្តៅ ១ យ៉ាងជាប់មាំ ហើយប្រាប់ថា៖ នាងឯងកុំដោកប្តីរបស់ នាងឲ្យអង្គុយនៅក្នុងកន្ត្រែងនេះ ហើយចូលដើរទៅចុះ ដើម្បីកុំឲ្យ លំបាកនឹងបញ្ជីរលើស្មារ ។ នាងនោះក៏ធ្វើតាមពាក្យដែលគេប្រាប់ ផ្ទុះហោះហើយចូលដើររៀង ៗ ទៅដល់ក្រុងពារាណសី ក៏ដាក់តាក់តុកតុះ អំពីក្បាលឈប់សម្រាកបរិភោគអាហារចំណី ក្នុងសាលាសម្រាប់ឲ្យទាន នោះ រួចហើយនឹងត្រាច់ផ្លាក់ដើរទៅមុខទៀត ។ គាប់ជួនជាពេលនោះ ព្រះបាទពោធិសត្វ ព្រះអង្គចេញទៅក្នុងពេនទាន ដើម្បីព្រះរាជទាន ចំណីដល់ពួកមនុស្សកម្សត់ទាំងឡាយៈ ជាយថ្ងៃលព្រះហស្តព្រះ អង្គឯង រួចហើយត្រឡប់ចូលទៅកាន់ព្រះរាជនិវេសន៍វិញ ។ ស្រាប់តែ ឃើញស្ត្រីនោះត្រង់ផ្លូវដែលទ្រង់យាងចូលទៅ ហើយក៏ត្រាស់សួរអស់ មនុស្សកម្សត់ទាំងឡាយថា៖ អ្វីនេះហ្នឹង! អស់ពួកមនុស្សទាំងនោះ ក៏ក្រាបបង្គំទូលថា៖ បពិត្រព្រះសម្មតិទេព នាងនេះជាស្ត្រីមានសេចក្ដី គោរពគោរពក្រែងដល់ប្ដីរបស់ខ្លួន ។ ព្រះបាទពោធិសត្វ ព្រះអង្គក៏ទ្រង់ ប្រើកដប់ឲ្យទៅហៅនាងនោះមក ហើយទ្រង់ជ្រាបច្បាស់ថាជាកិរិយា របស់ព្រះអង្គពីដើម ទើបទ្រង់ឲ្យគេលើកបុរសពិកលពិការនោះចេញ មកអំពីខាងក្នុងកន្ត្រែង ហើយត្រាស់សួរបុគ្គលទាំងពីរ ។ នាងនោះ

ក៏បានថ្វាយសារសព្វសេចក្តីក្រាបទូលសព្វគ្រប់តាមន័យដែលបានថ្វាយរួច
មកហើយក្នុងខាងដើម ។ ព្រះរាជាទ្រង់ត្រាស់សួរបញ្ជាក់ថា: នាងឯង
ក្រែងជាភរិយារបស់បទុមកុមារជោគីតាបស់ស្តេចឯណោះមែនឬ? ហើយ
ជាស្រីមានឈ្មោះយ៉ាងនេះ ភូទធីគណាមក្នុងដន្ត្រីរបស់អញ ហើយនាង
ឯងផិតក្បត់ចិត្តអញ ពេលល្បួចបង់ចិត្តប្រពិត្ត ស្រឡាញ់អាកំបុកនេះ
បានច្រានអញទំលាក់ទៅក្នុងជ្រោះភ្នំ មែនឬ? ឥឡូវនេះ នាងឯងនឹងលើល
ពាក្យសមកក្នុងទីនេះ ជាយស្មានថាអញស្លាប់បាត់ក្នុងជ្រោះភ្នំនោះទៅ
ហើយ ។ រួចហើយទ្រង់ត្រាស់បង្គាប់ទៅពួកពលរាជមាត្យថា: នែអ្នក
ទាំងឡាយពលគ្នា ចូរអ្នកទាំងឡាយយកអង្រែមកសំពង់សម្លាប់អាកំបុក
ចោរនិងអប្រិយនេះ ឲ្យធាប់ៗ ទៅ ហើយចូរនាំគ្នា កាត់ត្រចៀក ច្រមុះ
នៃស្រីបាបអប្រិយកាឡកណ្ណីអប្បលក្ខណ៍នេះឲ្យដាច់កុំទុកក៏ឡើយ ។
ព្រះពោធិសត្វដែលទ្រង់ធ្វើអាការៈគំរាមកំហែងយ៉ាងនេះ ដើម្បីបន្ទំ
សេចក្តីក្រោធតែប៉ុណ្ណោះទេ ប៉ុន្តែព្រះអង្គមិនបានឲ្យគេធ្វើដូច្នោះឡើយ ។
រួចហើយព្រះអង្គទ្រង់ប្រើរាជមាត្យឲ្យទៅដកកៅព្រាងលក្បាលនាងនោះ
ដូចដើមវិញ ហើយឲ្យដាក់អាកំបុកទៅក្នុងកៅព្រាងនោះ ហើយទ្រង់
ត្រាស់ឲ្យរាជមាត្យនាំចេញពកទៅតាលគ្យផុតអំពីព្រំប្រទល់ដែនរបស់
ព្រះអង្គ ។